# កម្មវិធីគាំទ្រវិស័យអប់រំកុមារដែលរស់នៅតំបន់ដាច់ស្រយាល

# (អេស្កាប់)

Educational Quality Improvement Program
Classrooms • Schools • Communities

# វគ្គតំរង់ទិសស្តីអំពីការជ្រើសរើសគ្រូសហគមន៍

សម្រាប់

# គណៈកម្មាធិការអប់រំសម្រាប់ទាំងអស់គ្នាថ្នាក់ឃុំ



## ការចូលរួមរបស់គណៈកម្មាធិការមូលដ្ឋាន
## រួមចំណែកលើកកំពស់បរិយាកាសសិក្សាតាមបែបកុមារមេត្រី

**កញ្ញា ២០០៥**

# មាតិកា


| | | ទំព័រ |
|---|---|---|
| I. | សេចក្តីផ្តើម | ២ |
| II. | ទំនាក់ទំនងជាមួយមជ្ឈដ្ឋាននានា ដែលសហគមន៍ត្រូវធ្វើដើម្បីគុណភាពអប់រំ | ៣ |
| III. | គោលបំណងសិក្ខាសាលា | ៣ |
| IV. | ខ្លឹមសារសិក្ខាសាលា | ៤ |
| V. | វិធីសាស្ត្រ | ៥ |
| VI. | វគ្គដែលផ្តើមដោយនិតិវិធី | ៥ |
| VII. | អ្វីដែលអ្នកចូលរួមរំពឹងថាត្រូវបានទទួលពេលចប់វគ្គ | ៦ |
| VIII. | ទីកន្លែងនិងពេលវេលា | ៦ |
| IX. | ការរៀបចំតុ | ៦ |
| X. | ចំនួនអ្នកចូលរួម | ៧ |
| XI. | ការវាយតំលៃវគ្គ | ៨ |

**ខ្លឹមសារសម្រាប់វគ្គលើកទី១:**

| | |
|---|---|
| មេរៀនទី១ | សេចក្តីផ្តើម: ការណែនាំឱ្យស្គាល់គ្នា គោលបំណងសិក្ខាសាលា ការបង្ហាញអំពីកម្មវិធីអេស្កាប់ គោលបំណងកម្មវិធី រចនាសម្ព័ន្ធកម្មវិធី និងរបៀបរបបការងាររបស់អេស្កាប់ |
| មេរៀនទី២ | បញ្ញត្តិកម្មវិធីសាលាកុមារមេត្រី |
| មេរៀនទី៣ | ការគ្រប់គ្រងគ្រូសហគមន៍ |
| មេរៀនទី៤ | អ្នកពាក់ព័ន្ធ ភាពជាម្ចាស់ និងការចូលរួម |

**ឧបសម្ព័ន្ធ:**

| | |
|---|---|
| ឧបសម្ព័ន្ធទី១: | កម្មវិធីអេស្កាប់ គោលបំណងកម្មវិធី រចនាសម្ព័ន្ធកម្មវិធី និងរបៀបរបបការងាររបស់អេស្កាប់ |
| ឧបសម្ព័ន្ធទី២: | លក្ខណៈវិនិច្ឆ័យក្នុងការជ្រើសរើសគ្រូសហគមន៍ |
| ឧបសម្ព័ន្ធទី៣: | សេចក្តីជូនដំណឹងពីការជ្រើសរើសគ្រូសហគមន៍ |
| ឧបសម្ព័ន្ធទី៤: | ពាក្យសុំបំរើការងារ |
| ឧបសម្ព័ន្ធទី៥: | បញ្ជីសង្ខេបឈ្មោះបេក្ខជនដែលត្រូវសំភាសន៍ |
| ឧបសម្ព័ន្ធទី៦: | កម្រងសំណួរសំភាសន៍ |
| ឧបសម្ព័ន្ធទី៧: | បញ្ជីឈ្មោះគ្រូសហគមន៍ដែលបានជ្រើសរើស |
| ឧបសម្ព័ន្ធទី៨: | តារាងផែនការជ្រើសរើសគ្រូសហគមន៍ |
| ឧបសម្ព័ន្ធទី៨: | កិច្ចសន្យា |

ឧបសម្ព័ន្ធទី១០: សកម្មភាពក្នុងជំហានបន្ទាប់ ក្នុងការជ្រើសរើសគ្រូសហគមន៍

## I. សេចក្តីផ្តើម

### ក- ការពុះពារដើម្បីសម្រេចការអប់រំសម្រាប់ទាំងអស់គ្នា

ចាប់តាំងពីមានសន្និសិទ្ធអន្តរជាតិ ស្តីអំពីការអប់រំសម្រាប់ទាំងអស់គ្នា នៅជំទៀម និងថ្មីៗនេះនៅទីក្រុងដាកា ដែលមាន១១៦ប្រទេសបានចូលរួម រួមទាំងប្រទេសកម្ពុជាផងនោះ បានសន្យាថាកុមារគ្រប់រូបនឹងត្រូវបានទទួលការអប់រំជាមូលដ្ឋាន ប្រកបដោយគុណភាពនៅឆ្នាំ២០១៥។ អង្គការក្រៅរដ្ឋាភិបាលជាច្រើន បានរួមចំនែកយ៉ាងខ្លាំងក្លា ក្នុងការធានាអោយកុមារកម្ពុជា មានសិទ្ធិទទួលការអប់រំពេញលេញ និងធ្វើអោយសម្រេចគោលដៅនៃការអប់រំសម្រាប់ទាំងអស់គ្នា។ ទោះយ៉ាងនេះក្តី នៅតែមានគំលាតគួរអោយកត់សំគាល់ រវាងគោលនយោបាយអប់រំនិងការអនុវត្តជាក់ស្តែង។ កត្តាចំនងៗមួយចំនួន ទាំងកត្តាផ្គត់ផ្គង់និងកត្តាតំរូវការ នៅបន្តធ្វើអោយរាំងស្ទះដល់គុណភាពអប់រំទូទាំងប្រទេស ជាពិសេសនៅតំបន់ដាច់ស្រយាល រួមមាន កង្វះគ្រូ កម្មវិធីសិក្សាមិនទាន់ឆ្លើយតបទៅនឹងការរស់នៅជាក់ស្តែងពេញលេញ ការចូលរៀនមិនទាន់ស្មើភាពនៅឡើយ។ ទាំងនេះ មួយផ្នែកបណ្តាលមកពីមាតាបិតាខ្វះថវិកាក្នុងការចំណាយទៅលើការសិក្សារបស់កូន និងផ្នត់គំនិតរបស់សហគមន៍ ដែលមិនទាន់អោយតំលៃខ្ពស់លើការអប់រំ។

### ខ- សេចក្តីត្រូវការ ការចូលរួមរបស់សហគមន៍

ការតាំងចិត្ត និងការចូលរួមរបស់សហគមន៍មានសារៈសំខាន់ណាស់ ក្នុងការធ្វើអោយកុមារទាំងអស់ទទួលបានការអប់រំដែលមានគុណភាព។ រដ្ឋាភិបាល ម្ចាស់ជំនួយ និងអង្គការក្រៅរដ្ឋាភិបាលតែឯកឯងមិនអាចផ្តល់ធនធានដែលត្រូវការនោះបានគ្រប់គ្រាន់ទេ គឺមានតែសហគមន៍ខ្លួនឯងប៉ុណ្ណោះ ដែលអាចចលនាបំផុសរកនិងផ្តល់ធនធានមនុស្ស សម្ភារនិងធនធានផ្សេងៗទៀតបាន។ សហគមន៍ក៏អាចប្រមូលផ្តុំនិងនាំមកនូវលំនាំបែបបទការងារផ្សេងៗជាច្រើនទៀត ដែលអាចធ្វើអោយការប្រតិបត្តិការងារថ្នាក់មូលដ្ឋាន មានដំណើរការស៊ីសង្វាក់គ្នាទៅនឹងគោលនយោបាយថ្នាក់ជាតិ។ និយាយរួម បើគ្មានការគាំទ្រនិងភាពជាម្ចាស់របស់សហគមន៍ នោះការងារទាំងឡាយពិតជាពុំអាចមាននិរន្តរភាពបានឡើយ។ តាមពិត សហគមន៍និងមាតាបិតាបានរួមចំនែកយ៉ាងច្រើនជាមួយនឹងការប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុងការឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់កុមារ។ ពួកគេបានចូលរួមក្នុងការងារមួយចំនួនដូចជា ការកែលំអហេដ្ឋារចនាសម្ព័ន្ធនិងការបង្កើតប្រព័ន្ធទឹកស្អាតក្នុងសាលារៀនជាដើម។ ទោះបីជាមានការចូលរួមចំនែកទាំងនេះក្តី សហគមន៍និងក្រុមគ្រួសារមួយចំនួនធំ ជាពិសេសនៅតាមតំបន់ជនបទដាច់ស្រយាលពុំបានត្រួតពិនិត្យនិងគ្រប់គ្រង ឬបានធ្វើដោយតិចតួចប៉ុណ្ណោះ ទៅលើការសិក្សារបស់កូន។ ការអប់រំត្រូវបានយល់ថាជាការទទួលខុសត្រូវរបស់រាជរដ្ឋាភិបាល។ សហគមន៍នៅមិនទាន់យល់នៅឡើយថា ការរួមចំនែកលើកកំពស់គុណភាពអប់រំ គឺជាការងាររបស់យើងទាំងអស់គ្នា រួមទាំងសហគមន៍ផងដែរ។ ពួកគេមិនទាន់ដឹងថា សហគមន៍

មានតួនាទីយ៉ាងសំខាន់ និងជាភ្នាក់ងារដែលធ្វើអោយមានការផ្លាស់ប្តូរ នោះឡើយ។ ដូច្នេះហើយ រាជរដ្ឋាភិបាល បានរួមសហការ ជាមួយអង្គការក្រៅរដ្ឋាភិបាលនឹងផ្តល់ការគាំទ្រដល់សហគមន៍ ក្នុងដំណើរការអភិវឌ្ឍនេះ។

**គ- តើអ្វីទៅជាកម្មវិធីអេស្កាប់ ហើយអេស្កាប់អាចជួយដូចម្តេចដើម្បីឆ្លើយតបនឹងការពុះពារទាំងនេះ?**

កម្មវិធីអេស្កាប់ គឺជាការផ្តួចផ្តើមដែលរៀបចំឡើងដើម្បីឆ្លើយតបទៅនឹងបញ្ហាទាំងឡាយ ដែលបានរៀបរាប់ខាងលើ ក្នុងគោលបំណងបង្កើនភាពងាយស្រួលក្នុងការចូលរៀនប្រកបដោយគុណភាព សំរាប់កុមារដែលទទួលសេវាអប់រំមិនគ្រប់គ្រាន់។ កម្មវិធីនេះ ទទួលថវិកាពីវិទ្យាស្ថានស្រាវជ្រាវអាមេរិក ហៅកាត់ថាអេ អាយ អ (AIR) និងកម្មវិធីកែលំអគុណភាពអប់រំ (EQUIP1)ក្រោមកិច្ចព្រមព្រៀងសហការ ជាមួយភ្នាក់ងារអភិវឌ្ឍអន្តរជាតិសហរដ្ឋអាមេរិក(USAID)។ កម្មវិធីអេស្កាប់ ផ្តោតទៅលើសមាសភាគធំ៧បី រួមមានការបំប៉នគ្រូ ភាពងាយស្រួលក្នុងការចូលរៀនប្រកបដោយគុណភាព និងភាពជាដៃគូរវាងសាលារៀននិងសហគមន៍។កម្មវិធី ក៏ផ្តោតជាសំខាន់ទៅលើការពង្រឹងការយល់ដឹង ជំនាញ បទពិសោធន៍និងអភិវឌ្ឍតិរិយាបទរបស់ដៃគូ ក្នុងការធ្វើឱ្យបញ្ញត្តិសាលាកុមារមេត្រី ក្លាយទៅជាការអនុវត្តជាក់ស្តែង។

ទាក់ទងទៅនឹងសមាសភាគទីបី គឺភាពជាដៃគូរវាងសាលារៀននិងសហគមន៍ កម្មវិធីផ្តោតលើការពង្រឹងរចនាសម្ព័ន្ធរបស់ក្រសួងអប់រំនិងរចនាសម្ព័ន្ធរដ្ឋាភិបាលនៅថ្នាក់មូលដ្ឋានដែលមានស្រាប់ ក្នុងគោលបំនងចលនាធនធានមូលដ្ឋាន ឱ្យរួមចំនែកសម្រេចគោលដៅរបស់កម្មវិធី គឺបង្កើនភាពងាយស្រួលចូលសាលារៀន។ ចំនុចនេះគឺធ្វើតាមរយៈកិច្ចសហការជិតស្និទ្ធជាមួយសហគមន៍ ជាពិសេសជាមួយគណៈកម្មាធិការអប់រំសម្រាប់ទាំងអស់គ្នាថ្នាក់ឃុំព្រមទាំងផ្តល់ការគាំទ្រ និងការគ្រប់គ្រងគ្រូសហគមន៍។ ចំនុចដែលយកចិត្តទុកដាក់នោះគឺ ការកសាងសមត្ថភាពដល់ដៃគូរបស់កម្មវិធី ដើម្បីអោយមានការចូលរួម ការផ្ទេរអំណាច ការវិភាគនិងដោះស្រាយបញ្ហា ការធ្វើផែនការ ការអនុវត្តផែនការនិងការត្រួតពិនិត្យទៅលើការអនុវត្តផែនការនោះ។

## II. ទំនាក់ទំនងជាមួយមជ្ឈដ្ឋាននានា ដែលសហគមន៍ត្រូវធ្វើដើម្បីគុណភាពអប់រំ

គណៈកម្មាធិការអប់រំសម្រាប់ទាំងអស់គ្នាថ្នាក់ឃុំ ត្រូវបានបង្កើតឡើងជាផ្លូវការ ដោយលេខាធិការដ្ឋានអប់រំសម្រាប់ទាំងអស់គ្នានៃក្រសួងអប់រំយុវជន និង កីឡាក្នុងគោលបំណងឱ្យគណៈកម្មាធិការនេះមានភាពសកម្មចូលរួមក្នុងការសម្រេចគោលដៅការអប់រំសម្រាប់ទាំងអស់គ្នានៅឆ្នាំ២០១៥។ ដូច្នេះ គណៈកម្មាធិការនេះគឺតំណាងឱ្យសម្លេងរបស់សមាជិកសហគមន៍និងមានតួនាទីយ៉ាងសំខាន់ ក្នុងការធ្វើការជិតស្និទ្ធជាមួយអង្គការក្រៅរដ្ឋាភិបាលដូចជាអេស្កាប់ រួមចំណែកជាមួយការខិតខំប្រឹងប្រែង របស់រាជរដ្ឋាភិបាល ដើម្បីផ្តល់សេវាអប់រំដែលមានគុណភាពឆ្លើយតបទៅនឹងតម្រូវការរៀនសូត្ររបស់កុមារទាំងអស់។ ដើម្បីធ្វើដូច្នេះបាន គណៈកម្មាធិការអប់រំសម្រាប់ទាំងអស់គ្នាថ្នាក់ឃុំ ក៏ដូចជាសមាគមមាតាបិតាសិស្ស គួរឈានទៅបំពេញតួនាទីបន្ថែមទៀត ក្រៅពីអ្វីដែលបានធ្លាប់ធ្វើកន្លងមក ដូចជាការសាងសង់អាគារជាដើម។ ការផ្ទេរអំណាចតាមរយៈការផ្តល់នូវចំណេះដឹងនិងបំនិនឬជំនាញ

អាចឱ្យពួកគេអាចធ្វើការជាមួយអ្នកពាក់ព័ន្ធជាច្រើនទៀត ដើម្បីដោះស្រាយផ្នែកនានាក្នុងប្រព័ន្ធអប់រំ ក្នុងនោះរួមមានធនធាន ដំណើរការ ខ្លឹមសារ និងគុណភាព។

១ កម្មវិធីគាំទ្រសេវាអប់រំ ដល់កុមារនៅតំបន់ដាច់ស្រយាល (ESCUP)

ឯកសារនេះផ្តោតទៅលើទំនាក់ទំនងរបស់សហគមន៍ជាមួយក្រុមអ្នកពាក់ព័ន្ធចំនួនបួនក្រុមៈ១) គណៈកម្មការកម្រងសាលារៀនមូលដ្ឋាននិងលោកគ្រូអ្នកគ្រូ ២) សិស្ស ៣) មាតាបិតា និង ៤) អង្គការក្រៅរដ្ឋាភិបាល/ អេស្កាប់។ ទំនាក់ទំនងរវាងក្រុមអ្នកពាក់ព័ន្ធ និងគណៈកម្មាធិការអប់រំសម្រាប់ទាំងអស់គ្នាថ្នាក់ឃុំ ត្រូវបានបង្ហាញ ក្នុងរូបភាព២.១ ដូចខាងក្រោមៈ

រូបភាព២.១: ទំនាក់ទំនងរវាងក្រុមអ្នកពាក់ព័ន្ធ និងគណៈកម្មាធិការអប់រំសម្រាប់ទាំងអស់គ្នាថ្នាក់ឃុំ




## III. គោលបំណងសិក្ខាសាលា

- ដើម្បីលើកកំពស់ការយល់ដឹងរបស់អ្នកចូលរួម អំពីបញ្ហាសំខាន់ៗនៃការអប់រំ។
- ដើម្បីបង្កើនសមត្ថភាពអ្នកចូលរួមជាពិសេស *គណៈកម្មាធិការអប់រំសម្រាប់ទាំងអស់គ្នាថ្នាក់ឃុំ* លើការគ្រប់គ្រងគ្រូសហគមន៍ រួមទាំងការជ្រើសរើសគ្រូ ជាដើម ។
- ដើម្បីបង្កើនសមត្ថភាពអ្នកចូលរួម ក្នុងកាធ្វើផែនការដែលអាចប្រើប្រាស់នូវយុទ្ធវិធីផ្សេងៗដើម្បីគាំទ្រការបង្រៀននិងរៀន ឈានទៅសម្រេចបរិយាកាសបែបកុមារមេត្រីក្នុងសាលារៀន។
- ដើម្បីឱ្យសហគមន៍និងអាជ្ញាធរមូលដ្ឋាន អាចធ្វើការប៉ាន់ប្រមាណនិងឱ្យអាទិភាពលើតម្រូវការសិក្សា ធ្វើផែនការដែលឆ្លើយតបនឹងតម្រូវការនោះ ព្រមទាំងអនុវត្តនិងត្រួតពិនិត្យលើផែនការរបស់ខ្លួន។
- ដើម្បីកំនត់សក្តានុពលរបស់អ្នកចូលរួម ក្នុងការបង្កើតតួនាទីនិងភារកិច្ចគាំទ្រកាបង្រៀននិងរៀន។

- ដើម្បីជំរុញដំណើរការវិមជ្ឈការ ដែលក្រសួងបានធ្វើក្នុងជំហានដំបូង ក្នុងការផ្ទេរការទទួលខុសត្រូវដល់ថ្នាក់មូលដ្ឋាន។

## IV. ខ្លឹមសារសិក្ខាសាលា

### ខ្លឹមសារសម្រាប់វគ្គលើកទី១:

មេរៀនទី 1. សេចក្តីផ្តើម ការណែនាំឱ្យស្គាល់គ្នា គោលបំណងសិក្ខាសាលា ការបង្ហាញអំពីកម្មវិធី អេស្កាប់ គោលបំណងកម្មវិធី រចនាសម្ព័ន្ធកម្មវិធី និង របៀបរបបការងាររបស់អេស្កាប់

មេរៀនទី 2 បញ្ញត្តិកម្មវិធីសាលាកុមារមេត្រី

មេរៀនទី 3 ការគ្រប់គ្រងគ្រូសហគមន៍

មេរៀនទី 4 អ្នកពាក់ព័ន្ធ ភាពជាម្ចាស់ និងការចូលរួម

## V. វិធីសាស្រ្ត

យុទ្ធវិធីសំរាប់សាលាកុមារមេត្រី តម្រូវឱ្យគ្រូប្រើវិធីសាស្រ្តសកម្មដែលមានការចូលរួមពីសិស្សនៅក្នុងថ្នាក់រៀន។ ដូច្នេះអ្នកសម្របសម្រួលនៅក្នុងសិក្ខាសាលានេះ គួរប្រើវិធីសាស្រ្តដូចគ្នានេះដែរជាមួយអ្នកចូលរួមនៅក្នុង វគ្គនេះ ដើម្បីបង្ហាញឱ្យឃើញជាក់ស្តែងនូវគោលគំនិតថាតើ "មេត្រីភាព " មានន័យដូចម្តេច។ កំហុសរួមមួយដែលអ្នកសម្របសម្រួលតែងមានជានិច្ចកាលនោះ គឺការចំណាយពេលនិយាយតែម្នាក់ឯងច្រើនពេកដោយប្រើ វិធីសាស្រ្ត "ប្រើដីសនិងនិយាយ " ដែលធ្វើឱ្យបរិយាកាសខ្វះការចូលរួម ស្ងាត់ស្ងៀម និងខ្វះក្តីរីករាយនិងអំណរសាទរ។ ចំនុចខាងក្រោមនេះ គឺជាវិធីសាស្រ្តដែលប្រើក្នុងសិក្ខាសាលានេះ:

- ការពន្យល់ បកស្រាយបង្ហាញ
- ការបំផុសគំនិតក្នុងក្រុមធំ ពិភាក្សានិងធ្វើការក្នុងក្រុមធំ
- ការងារជាដៃគូ
- ការពិភាក្សាក្នុងក្រុមតូច
- ការដើរដើរក្នុងថ្នាក់ មើលលទ្ធផលតាមក្រុមនិមួយៗដែលបិទលើជញ្ជាំង
- ការសំដែងតួ
- ករណីសិក្សា
- ល្បែងថាមពល និងល្បែងសិក្សា
- ការបង្ហាញគំរូ

*<u>សំគាល់:</u>ទោះយ៉ាងណាក្តី វិធីសាស្រ្តដែលប្រើ ត្រូវតែមានភាពបត់បែនស្របទៅតាមកំរិតយល់ដឹង ចំណង់ចំណូលចិត្ត និងមជ្ឈដ្ឋានរស់នៅរបស់អ្នកចូលរួម។ គួរប្រើរូបភាពនិងវត្ថុតាងឱ្យបានច្រើនតាមដែលអាចធ្វើបាន បើអ្នកចូលរួមភាគច្រើនមិនសូវចេះអាននិងសរសេរ។*

## VI. វគ្គដែលផ្តើមដោយនីតិវិធី

- ការផ្តើមដោយសកម្មភាពល្បែងបំបាមពល ល្បែងកំសាន្ត ឬល្បែងសិក្សា ដែលបង្កបរិយាកាសស្និទ្ធស្នាល ។
- ការបំភ្លឺពីចំនុចដែលទាក់ទងនឹងសម្ភារ ថវិកាដែលត្រូវទទួល និងសំណងនៃការធ្វើដំណើរ( បើសិនជាមាន) និងចំនុចផ្សេងៗ ដែលយល់ថាអ្នកចូលរួមគួរដឹងជាមុន ។
- ការត្រួតពិនិត្យមើលថាតើមានមតិជំទាស់ឬមតិស្រប ហើយបបង្ហាញគោលបំនងសិក្ខាសាលា ។
- ការពិនិត្យឡើងវិញលើខ្លឹមសារនិងកាលវិភាគ សម្រាប់សិក្ខសាលា ។ បញ្ជាក់ថាកាលវិភាគនេះអាចមានការផ្លាស់ប្តូរខ្លះ បើមានការចាំបាច់ ។
- ការបង្កើតបទបញ្ជាផ្ទៃក្នុងសម្រាប់វគ្គ ដូចជាការគោរពពេលវេលា ការបន្ថយសម្លេងទូរស័ព្ទ ការចូលរួមបញ្ចេញយោបល់ ការមិននិយាយកាត់អ្នកដទៃពេលគេកំពុងនិយាយ ការជួយការងារផ្សេងៗ ទាក់ទងនឹងវគ្គ ។ល ។
- ប្រសិនបើមានមេរៀនដូចជា ការគូរផែនទីសាលារៀន ប្រហែលជាត្រូវបញ្ជាក់ឱ្យអ្នកចូលរួមដឹងជាមុន ដើម្បីត្រៀមលក្ខណៈប្រមូលព័ត៌មានសម្រាប់សកម្មភាពនោះ ។ បញ្ជាក់ឱ្យច្បាស់ពីអ្វីដែលត្រូវការ និងពីដំណើរការដែលនឹងត្រូវធ្វើ ។
- ឱ្យអ្នកចូលរួមបង្ហាញពីការរំពឹងទុករបស់គេ ចំពោះវគ្គ ( តើគេសង្ឃឹមថា គេបានរៀនអ្វីខ្លះ ពីវគ្គនេះ?) ។

## VII. អ្វីដែលអ្នកចូលរួមរំពឹងថាត្រូវបានទទួលពេលចប់វគ្គ

- <u>សម្រាប់អ្នកចូលរួមម្នាក់ៗ:</u>
  - ត្រូវមានផែនការលំអិតដើម្បីអនុវត្តពេលខាងមុខ ។
  - ត្រូវមានឯកសារមេរៀនទាំងអស់ និងសម្ភារដែលត្រូវការចាំបាច់យកទៅជាមួយ ដូចជាលក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសគ្រូសហគមន៍ ប័ណ្ណផ្សាយដំណឹងជ្រើសរើស ពាក្យសុំបំរើការងារ កម្រងសំណួរសំភាសន៍ និងកិច្ចសន្យាជាដើម ។
  - គួរមានបញ្ជីឈ្មោះទំនាក់ទំនង អាស័យដ្ឋាន និង លេខទូរស័ព្ទបើអាចមាន ដើម្បីងាយស្រួលក្នុងការទាក់ទងគ្នា ។
- <u>តាមក្រុម</u>: អ្នកចូលរួមអាចនឹងចុះស្រាវជ្រាវរកព័ត៌មានបន្ថែម បំពេញផែនទីសាលារៀន បើចាំបាច់ ។

## VIII. ទីកន្លែងនិងពេលវេលា

អ្នកសម្របសម្រួលគួរពិភាក្សាជាមួយមេឃុំជាមុន អំពីទីកន្លែងសម្រាប់សិក្ខាសាលា ដើម្បីកំនត់ទីកន្លែងសមស្របដែលអ្នកចូលរួមទាំងអស់អាចធ្វើដំណើរមកចូលរួមបាន ។ ជូនដំណឹងដល់អ្នកចូលរួម២ឬ៣ថ្ងៃ មុនពេលសិក្ខាសាលា ដើម្បីធានាវត្តមានពេញលេញ ។ វគ្គដំបូងមានរយៈពេល២ថ្ងៃ ហើយមានការប្រជុំប្រចាំខែជាទៀង ទាត់

ដើម្បីពិនិត្យទៅលើការអនុវត្តសកម្មភាព ផ្លាស់ប្តូរបទពិសោធន៍និងបញ្ហាដែលកើតមាន ហើយរកដំណោះស្រាយរួមគ្នាឬផ្តល់ការបំប៉នលើខ្លឹមសារណាមួយដែលយល់ថាជាការរួមចំណែកក្នុងការអភិវឌ្ឍសមត្ថភាពអ្នកចូល រួម។ ក្នុងបីខែម្តង អាចមានសិក្ខាសាលារំលឹកចំនួន២ថ្ងៃម្តង ប្រសិនបើមានការចាំបាច់។ សិក្ខាសាលាទាំងនេះគួរធ្វើយ៉ាងណាកុំឱ្យស្របគ្នាជាមួយថ្ងៃបុណ្យទាន ឬរដូវដាំដុះប្រមូលផលសំខាន់ៗ ដែលបង្កអោយអ្នកចូលរួមត្រូវអាក់ខាន។

## IX. ការរៀបចំតុ

នៅក្នុងបន្ទប់រៀនគួរតែធំល្មម ចៀសវាងការអង្គុយពីរជួរ ហើយគួរមានពន្លឺគ្រប់គ្រាន់។ តុអង្គុយគួររៀបជារាងអក្សរ U សម្រាប់សកម្មភាពក្រុមធំ។ ការអង្គុយលើកន្ទេលជារង្វង់មូល ក៏អាចជាវិធីមួយដ៏ល្អ ដែលធ្វើឱ្យអ្នកចូលរួមអាចអង្គុយតាមសម្រួល អាចធ្វើឱ្យគេមានអារម្មណ៍ថាសិក្ខាសាលាមានលក្ខណៈសាមញ្ញមិនផ្លូវការ គេអាចចូលរួមមានយោបល់ឬធ្វើសកម្មភាពដោយផុលផុសបាន។ រៀងរាល់ថ្ងៃ អ្នកចូលរួមគួរដូរកន្លែងអង្គុយ ហើយអ្នកនៅខាងក្រោយ គួរតែត្រូវបានយកចិត្តទុកដាក់លើកទឹកចិត្តពីអ្នកសម្របសម្រួលឱ្យបានច្រើន ឱ្យគេបានបញ្ចេញយោបល់។ ម្យ៉ាងទៀត អ្នកចូលរួមនិងអ្នកសម្របសម្រួលគួរមានប័ណ្ណឈ្មោះ ហើយប័ណ្ណឈ្មោះនោះគួរនៅបានប្រើប្រាស់រហូតចប់វគ្គ ដើម្បីងាយស្រួលក្នុងការប្រាស្រ័យទាក់ទងក្នុងក្រុម។



## X. ចំនួនអ្នកចូលរួម

ចំនួនអ្នកចូលរួមយ៉ាងច្រើនបំផុត មិនគួរមិនលើសពី២៥នាក់ ហើយសមាសភាពគួរមានដូចខាងក្រោមៈ

- មេឃុំ (Commune Chief) *
- មេភូមិ (Village Chief) *

- ប្រធានកំរង (Cluster School Director) *
- នាយកវិទ្យាល័យ បើមានវិទ្យាល័យនៅទីនោះ (High School Director) *
- នារីអភិវឌ្ឍភូមិ/ឃុំ ទទួលបន្ទុកស្ត្រីនិងកុមារ (Women/Child Focus Person) *
- ប្រធានគណៈកម្មការទ្រទ្រង់សាលា (School Support Committee (SSC) Chairpersons)
- ព្រះសង្ឃ  (Monk)
- អ៊ីម៉ាំ (Imam)
- តំណាងជនជាតិម្នាក់ឬពីរនាក់ (one or two representatives from minority groups)

*<u>បញ្ជាក់:</u> សញ្ញាផ្កាយ (*) បញ្ជាក់ពីសមាជិក ដែលត្រូវបានចាត់តាំងជាផ្លូវការ ។*

*ចំនួនប្រធានគណៈកម្មការទ្រទ្រង់សាលា និងអ្នកចូលរួមដទៃទៀតដែលត្រូវអញ្ជើញ (ជាអ្នកដែលមិនមែនជា សមាជិកគណៈកម្មាធិការអប់រំសម្រាប់ទាំងអស់គ្នា) គឺផ្អែកទៅតាមឃុំតូចឬធំ ហើយជាពិសេសគឺចំនួនមេភូមិដែលចូលរួម ។ បើសិនជាឃុំមានច្រើនភូមិ ប្រហែលជាពុំអាចអញ្ជើញតំណាងគណៈកម្មការទ្រទ្រង់សាលាបានឡើយ ព្រោះយើង ចង់រក្សាចំនួនអ្នកចូលរួមត្រឹមតែ២៥នាក់ ឬតិចជាងនេះ ។*

## XII. ការវាយតំលៃវគ្គ

ការប្រើទំរង់បែបសាមញ្ញក្នុងការប្រមូលព័តិមានត្រលប់ពីអ្នកចូលរួម នឹងអាចជួយដល់អ្នកសម្របសម្រួល ក្នុងការធ្វើផែនការនៅពេលខាងមុខ ។ បើក្នុងសិក្ខាសាលាមានគ្នាតិចល្មម អ្នកចូលរួមអាចផ្តល់ការវាយតំលៃរបស់ខ្លួនលើវគ្គដោយផ្ទាល់មាត់ តាមរយៈសកម្មភាពដូចជាល្បែងបោះបាល់[1] ។ ពួកគេមានឱកាសធ្វើការឆ្លុះបញ្ចាំងទៅលើអ្វីដែលគេបានរៀន និងទៅលើដំណើរការវគ្គ ។ ។ឧទាហរណ៍ ការវាយតំលៃគួរស្វែងយល់ថា:

- តើអ្នកចូលរួមបានរៀនពីខ្លះ?
- តើសម្រេចគោលបំនងសិក្ខាសាលាឬទេ?
- តើសម្រេចការរំពឹងទុករបស់អ្នកចូលរួមឬទេ ?
- តើសិក្ខាសាលានេះ មានលក្ខណៈសាមញ្ញអាចយកទៅអនុវត្តបានឬទេ?
- តើមានការចូលរួមពីសិក្ខាកាមឬទេ?

---

[1] <u>សំភារមានៈ</u>ធុង (សម្រាម) ពីរ និងក្រដាស A 4 ដែលបោះចោល (scrap papers) ។

<u>របៀបលេង:</u> អ្នកចូលរួមអង្គុយជាពីរជួរ ។ ម្នាក់ៗបានទទួលក្រដាសពីរសន្លឹក ដែលត្រូវឈ្លោលវាធ្វើឱ្យទៅជាបាល់ពីរ ។ បាល់មួយតាងឱ្យអ្វីដែលគេយល់ថាជាចំនុចល្អ(បីចំនុច) និងបាល់មួយទៀតតាងឱ្យអ្វីដែលគេយល់ថាមិនល្អ (យ៉ាងហោចណាស់មួយចំនុច) ដែលគេមិនចូលចិត្តនៅក្នុងវគ្គនេះ ។ ម្នាក់ម្តងៗ អ្នកចូលរួមបោះបាល់ដែលមានប្រយោជន៍ ដែលគិតថានឹងយកវាទៅជាមួយទៅដាក់ធុងមួយ ហើយនិយាយប្រាប់ទាំងអស់គ្នាពីអ្វីដែលខ្លួនពេញចិត្ត រួចហើយបោះបាល់មួយទៀតទៅក្នុងធុងសម្រាមមួយទៀត និងរៀបរាប់អ្វីដែលខ្លួនមិនចូលចិត្តដែលគិតថានឹងបោះវាចោលនៅទីនេះ ។ ធ្វើដូចនេះពីម្នាក់ទៅម្នាក់ រហូតដល់ចប់ ។

- តើមានសម្ភារដែលត្រូវការប្រើក្នុងវគ្គនេះដែរឬទេ?
- តើកាលវិភាគឬរបៀបវារៈ មានលក្ខណៈជាក់ស្តែងសមស្របឬទេ?
- តើបរិយាកាស មានលក្ខណៈស្និទ្ធស្នាលនិងនាំមកនូវការចូលរួមគ្រប់គ្នាឬទេ?
- តើអ្នកចូលរួមគិតថាអ្វីដែលចាប់អារម្មណ៍ជាងគេ និងធុញថប់ជាងគេ ហើយដោយសារមូលហេតុអ្វី?
- តើអ្វីខ្លះជាចំនុចល្អ និងចំនុចគួរកែលំអ?



| ខ្លឹមសារនិងសេចក្តីសង្ខេប:<br><br>រយៈពេល: | ១. **ការផ្តើមសិក្ខាសាលា:** នេះជាការចាប់ផ្តើម ដោយអ្នកសម្របសម្រួល និងអ្នកចូលរួមណែនាំខ្លួនម្តងម្នាក់ៗ ដើម្បីបានស្គាល់គ្នា បន្ទាប់មកបង្ហាញពីខ្លឹមសារ កាលវិភាគ និងគោលបំណងសិក្ខាសាលា។<br>៣០នាទី | |
|---|---|---|
| **សម្ភារដែលត្រូវការ:** | ○ ផ្ទាំងក្រដាសធំដែលមានសរសេរស្រាប់អំពីខ្លឹមសារមេរៀននិងកាលវិភាគ<br>○ ផ្ទាំងក្រដាសធំដែលមានសរសេរស្រាប់អំពីគោលបំណងសិក្ខាសាលា<br>○ ប័ណ្ណស (អាចប្រើក្នុងការសរសេរឈ្មោះ ដាក់លើតុម្នាក់មួយៗ បើយល់ថាគួរមាន) | |
| វត្ថុបំណង | *សកម្មភាពអ្នកសម្របសម្រួល* | *សកម្មភាពអ្នកចូលរួម* |
| | ១.១. ការណែនាំឱ្យស្គាល់គ្នា<br>O អ្នកសម្របសម្រួលចាប់ផ្តើមដោយការស្វាគមន៍ដ៏កក់ក្តៅដល់អ្នកចូលរួមទាំងអស់ ហើយបន្តដោយការណែនាំខ្លួនម្នាក់ម្តងៗ។ ការណែនាំនេះមានសារៈសំខាន់ ក្នុងការចាត់ចែងការអង្គុយតាមក្រុម ទៅតាមកម្រង តាមសាលា ឬតាមភូមិ ដើម្បីងាយស្រួលក្នុងការធ្វើការរួមគ្នា ដូចជាការគូរផែនទីជាដើម ។<br>១.២.ការចាត់ចែងអង្គុយតាមក្រុម<br>O បន្ទាប់ពីការណែនាំរួច អ្នកសម្របសម្រួល គួរឱ្យអ្នកចូលរួមអង្គុយតាមភូមិឬតាមសាលា។ ធ្វើដូចនេះបាន គួរផ្គុំតុសម្រាប់គ្នា៥ឬ៦នាក់មួយក្រុម ហើយរៀបជាអក្សរ U ជាជាងរៀបតុជាជួរ ព្រោះថាការអង្គុយជាជួរជាការល្អសម្រាប់ការងារជាបុគ្គលតែធ្វើឱ្យអ្នកចូលរួមពុំមានឱកាសពេញលេញក្នុងការប្រាស្រ័យទាក់ទង ឬពិភាក្សាគ្នាជាក្រុមឡើយ។<br>១.៣.គោលបំណងសិក្ខាសាលា<br>O អ្នកសម្របសម្រួលបិទផ្ទាំងក្រដាសអំពីខ្លឹមសារលើក្តារខៀនម្ខាង និងគោលបំណងសិក្ខាសាលា ព្រមទាំងលទ្ធផលដែលត្រូវបានពីសិក្ខាសាលនេះនៅលើក្តារខៀនម្ខាងទៀតឬលើជញ្ជាំង។<br>O ទុកពេលឱ្យអ្នកចូលរួមអានស្ងាត់ៗ និងសួរសំណួរ។<br>O សួរសំណួរទៅអ្នកចូលរួមវិញម្តង ដើម្បីធ្វើតេស្តលើការយល់ដឹង។<br>ឧទាហរណ៍:<br>តើសិក្ខាសាលានេះមានប៉ុន្មានលើក / វគ្គ?<br>តើត្រូវធ្វើអ្វីខ្លះ នៅចន្លោះវគ្គទាំងពីរ?<br>តើអ្វីដែលជាលទ្ធផលសំខាន់ ដែលត្រូវបានពីសិក្ខាសាលនេះ?<br>តើផែនទីសាលារៀនដែលបានគូរ ប្រើដើម្បីអ្វី? | O អ្នកចូលរួមប្រាប់ឈ្មោះ តួនាទី ភូមិដែលរស់នៅ ..។<br><br><br><br><br>O អ្នកចូលរួមរៀបចំក្រុមដោយខ្លួនឯង។<br><br><br><br><br>O អ្នកចូលរួមអាននិងសួរអ្នកសម្របសម្រួលបកស្រាយ។<br>O អ្នកចូលរួមផ្តល់ចម្លើយ |

| មេរៀនទី ៣ : ការគ្រប់គ្រងគ្រូសហគមន៍ | | |
|---|---|---|
| **ខ្លឹមសារនិងសេចក្តីសង្ខេបៈ**<br><br>**រយៈពេលៈ** | **៣.១: លក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសគ្រូសហគមន៍:** ផ្នែកនេះ ផ្តល់ឱកាសឱ្យអ្នកចូលរួមបានពិភាក្សាអំពី លក្ខណៈសម្បត្តិគ្រូសហគមន៍ ដែលគេពេញចិត្ត និងដំណើរការជាយុទ្ធសាស្ត្រ ក្នុងការជ្រើសរើស ។<br>៦០នាទី | |
| **សម្ភារដែលត្រូវការៈ** | ○ ផ្ទាំងក្រដាសធំៈ លក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសគ្រូសហគមន៍<br>○ ឯកសារចែកទី២ៈ លក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសគ្រូសហគមន៍ | |
| *វត្ថុបំណង* | *សកម្មភាពអ្នកសម្របសម្រួល* | *សកម្មភាពអ្នកចូលរួម* |
| អ្នកចូលរួមអាចៈ<br>/ បង្កើតលក្ខណៈវិនិច្ឆ័យសម្រាប់គ្រូសហគមន៍<br><br>/ រៀបរាប់អំពីលំនាំនៃការរើសគ្រូសហគមន៍ | **៣.១.១. *រំលឹកអំពីស្ថានភាពបច្ចុប្បន្នទាក់ទងនឹងការខ្វះគ្រូៈ***<br>❑ ចាប់ផ្តើមដោយសួរសំណួរៈ<br>? តើកុមារប៉ុន្មាន %នៅក្នុងឃុំនេះ ដែលមិនបានចូលរៀន?<br>? តើជនជាតិមានប៉ុន្មាន %នៅក្នុងឃុំនេះ?<br>? តើមានគ្រូប៉ុន្មាននាក់នៅក្នុងឃុំនេះ ដែលជាជនជាតិ?<br>? តើក្នុងសាលាមានបញ្ហាខ្វះគ្រូឬទេ?<br>? តើសហគមន៍បានដោះស្រាយដូចម្តេចចំពោះបញ្ហានេះ?<br>❑ បង្ហាញលទ្ធផលនៃការអង្កេតដោយអេស្កាប់ដល់អ្នកចូលរួម (ចំនួនគ្រូក្របខ័ណ្ឌ គ្រូកិច្ចសន្យាគ្រូពីរពេល ផលធៀបសិស្ស / គ្រូ) ។<br>[ មកដល់ពេលនេះ បង្ហាញចំនួនកូតាគ្រូសហគមន៍តាមសាលា (ដែលផ្អែកតាមលទ្ធផលនៃការអង្កេតនិងថវិកាដែលមាន) ។ ]<br>❑បញ្ជាក់ថាអេស្កាប់នឹងធ្វើការជាមួយ CEFACsឬ LCSCsក្នុងការជ្រើសរើសគ្រូសហគមន៍ជួយកាត់បន្ថយការខ្វះគ្រូនៅតាមសាលា ។<br>**៣.១.២. *លក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសគ្រូសហគមន៍ៈ***<br>❑ ទុកពេលឱ្យអ្នកចូលរួមគិតអំពីស្ថានភាពជាក់ស្តែងអពីសាលា កុមារ កុមារ ជនជាតិនិងភាសាដែលគេនិយាយ...ហើយគិតថាតើមនុស្សបែបណាដែលអាច ធ្វើជាគ្រូបង្រៀនដល់កុមារបាន ។<br>/ ចែក ***ឯកសារទី២*** ដល់អ្នកចូលរួម ។ប្រៀបធៀបនឹងគំនិតដែលពួកគេ | / អ្នកចូលរួមឆ្លើយនឹងសំណួរ<br><br><br>/ អ្នកចូលរួមសួរសំណួរ និងពិភាក្សា<br><br><br>/ អ្នកចូលរួមគិតនិងកត់ត្រាក្នុងសៀវភៅ<br><br>/ អ្នកចូលរួមអានឯកសារទី១ ហើយពិភាក្សាបន្ថែមឬកែដើម្បីកំនត់លក្ខណៈវិនិច្ឆ័យដែលពេញចិត្ត ។ |

| | | |
|---|---|---|
| | បានគិតទៅលើលក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសគ្រូសហគមន៍។<br>/ បូកសរុប។<br>**៣.១.៣. <u>ការផ្តល់ទម្ងន់លើចំនុចនិមួយៗក្នុងលក្ខណៈវិនិច្ឆ័យ:</u>**<br><u>សំណួរ:</u><br>**?** តើចំណុចទាំងអស់នៅក្នុងបញ្ជីលក្ខណៈវិនិច្ឆ័យនេះ គួរមានទម្ងន់ស្មើគ្នា ឬខុសគ្នា បើគិតអំពីភាពសំខាន់របស់វា? តើវាសំខាន់ដូចៗគ្នាឬទេ?<br>**?** គួរធ្វើយ៉ាងណាដើម្បីឱ្យការជ្រើសរើសលើកទី១បង្កើតបានបញ្ជីឈ្មោះ អ្នកត្រូវមកសំភាសន៍ បានសមស្របតាមសេចក្តីត្រូវការ?<br>/ ពិភាក្សាក្នុងក្រុមតូច កំនត់ភាពសំខាន់ របស់ចំនុចនិមួយៗ។<br>/ ធ្វើការប្រៀបធៀបលទ្ធផលតាមក្រុម<br>/ បូកសរុប<br>*ឧ:ពេលមើលពាក្យសុំ បើបេក្ខជនមិនមែនរស់នៅក្នុងភូមិចំណុះសាលាទេ គឺត្រូវបានដកចេញ ដោយមិនអាចជាប់ឈ្មោះសំភាសន៍ទេ។* | / អ្នកចូលពិភាក្សាក្នុងក្រុមធំ ហើយឆ្លើយ:<br>មិនគួរមានទម្ងន់ស្មើគ្នា ទេ ខ្លះសំខាន់ខ្លាំងខ្លះមិនសូវសំខាន់។ ឧ:អ្នករស់នៅក្នុងភូមិពិតជាចំនុច សំខាន់ណាស់ ។<br><br>/ អ្នចូលរួមអាចកំនត់:<br>សំខាន់បំផុត : ៣<br>សំខាន់ល្មម : ២<br>បន្ទាប់បន្សំ : ១ |
| **ខ្លឹមសារនិងសេចក្តីសង្ខេប:**<br><br>**រយៈពេល:** | **៣.២: ការប្រកាសផ្សាយជ្រើសរើសគ្រូសហគមន៍:** ផ្នែកនេះ គឺចង់បានគំនិតពីអ្នកចូលរួម អំពីវិធីផ្សេងៗក្នុងការប្រកាសផ្សាយដំណឹងដែលមានប្រសិទ្ធភាព។<br>៦០នាទី | |
| **សម្ភារដែលត្រូវការ:** | ○ ឯកសារចែកទី៣: សេចក្តីជូនដំណឹង<br>○ ផ្ទាំងក្រដាសធំ ហ្វឺត ស្កុត | |
| ***វត្ថុបំណង*** | ***សកម្មភាពអ្នកសម្របសម្រួល*** | ***សកម្មភាពអ្នកចូលរួម*** |
| អ្នកចូលរួមអាច:<br>/ កំនត់វិធីផ្សេងៗក្នុងការផ្សព្វផ្សាយប្រកាសដំណឹង។<br><br>/ ពិនិត្យនិងកែសម្រួលសេចក្តីប្រកាស។ | **៣.២.១. <u>ការកំនត់វិធីប្រកាសជូនដំណឹង:</u>**<br>/ សួរអ្នកចូលរួមថា: ធ្វើយ៉ាងណាទើបគេដឹងថា យើងត្រូវការបេក្ខជន មកដាក់ពាក្យ?<br>/ សរសេរចម្លើយលើក្តារខៀន។<br>/ ឱ្យក្រុមធំទាំងមូល សម្រេចយកវិធីដែលល្អ ដែលយល់ថាសមស្របបំផុត នៅក្នុងមូលដ្ឋានរបស់គេ ដែលគេយល់ថាមានប្រសិទ្ធភាព។<br>/ ចំពោះវិធីនិមួយៗ សួរសំណួរបន្ត: អ្នកណាជាអ្នកសម្របសម្រួល អ្នកណាចូលរួម នៅឯណា ពេលណា ត្រូវការសម្ភារអ្វីខ្លះ ប្រាក់ប៉ុន្មាន?<br>/ បូកសរុប និងកត់ត្រាចម្លើយទុក។<br>**៣.២.១. <u>ការពិនិត្យនិងកែសម្រួលពង្រាងសេចក្តីជូនដំណឹង</u>**<br>/ ចែក<u>***ឯកសារទី៣***</u> ស្តីអំពីសេចក្តីជូនដំណឹងទៅតាមក្រុមតូច | អ្នកចូលរួមផ្តល់ចម្លើយ:<br>❑ បិទសេចក្តីប្រកាសនៅកន្លែងសាធារណ:<br>❑ ប្រជុំតាមភូមិដើម្បីផ្សព្វផ្សាយ<br>❑ ប្រជុំតាមវត្តឬវិហារឥស្លាម<br>❑ ចែកលិខិតចំផ្ទះដែលអាចមានបេក្ខជនដាក់ពាក្យ ដូចជាផ្ទះដែកមានសិស្សរៀនចប់ថ្នាក់ទី៩ ជាដើម។<br>ក្រុមនិមួយៗអានហើយពិភាក្សា |

| | | |
|---|---|---|
| | ដើម្បីពិនិត្យ ។<br>/ ចែក***ឯកសារទី៣*** តាមចំនួនសន្លឹកដែលត្រូវការដើម្បីប្រើប្រាស់ពេលប្រតិបត្តិការផ្សាយដំណឹង ។ | គ្នាក្រុមអាចកែសម្រួលបើយល់ថាជាការចាំបាច់ ។<br>ក្រុមតូចសរសេរលើផ្ទាំងក្រដាសធំ បើត្រូវយកទៅបិទផ្សាយ ។ |
| **ខ្លឹមសារ និងសេចក្តីសង្ខេប:**<br><br>**រយៈពេល:** | **៣.៣: ការដាក់ពាក្យនិងបង្កើតបញ្ជីសង្ខេបលើកទី១:** ផ្នែកនេះ ផ្តល់ឱកាសឱ្យអ្នកចូលរួមបានអនុវត្តបំពេញទំរង់ពាក្យសុំ និងហាត់ធ្វើបញ្ជីសង្ខេបលើកទី១ ។ ជាមួយគ្នានេះដែរ អ្នកចូលរួមបានយល់ច្បាស់ពីគោលការណ៍ទាក់ទងនឹងការដាក់ពាក្យ ។<br><br>៦០នាទី | |
| **សម្ភារដែលត្រូវការ:** | ○ ឯកសារចែកទី៤: ទំរង់ពាក្យសុំបំរើការងារ<br>○ ឯកសារចែកទី៥: បញ្ជីសង្ខេបលើកទី១<br>○ ប៉ុស្ទ័រ: គោលការណ៍សង្ខេបទាក់ទងនឹងការដាក់ពាក្យ | |
| **វត្ថុបំណង** | ***សកម្មភាពអ្នកសម្របសម្រួល*** | ***សកម្មភាពអ្នកចូលរួម*** |
| អ្នកចូលរួមអាច:<br>/ រៀបរាប់ពីដំណើរការនៃការដាក់ពាក្យ ។<br><br>/ ហាត់បង្កើតបញ្ជីសង្ខេប<br><br>/ កំណត់បេក្ខជនដែលមានសក្តានុពល ដើម្បីមក ធ្វើការសំភាសន៍ ។ | **៣.៣.១. <u>ទំរង់ពាក្យសុំ</u>:**<br>/ សួរទៅក្រុមធំ: តើអ្នកគិតថា ក្រោយពីការផ្សាយដំណឹង តើអ្នកដែលចាប់អារម្មណ៍នឹងការងារនេះ នឹងធ្វើដូចម្តេច?<br>/ ចែកឯកសារទី៤ ដល់អ្នកចូលរួមគ្រប់គ្នា ។<br>/ ឱ្យអ្នកចូលរួមម្នាក់ៗ ធ្វើជាអ្នកដាក់ពាក្យសុំ ធ្វើជាគ្រូសហគមន៍ ហើយបំពេញទំរង់ពាក្យសុំនេះ ។<br>/ ឱ្យអ្នកចូលរួមពិនិត្យរកដៃគូ ហើយកិច្ចការដែលបានបំពេញទៅវិញទៅមក ។<br>/ ឆ្លុះបញ្ចាំងលើការបំពេញទំរង់: តើផ្នែកណាដែលងាយស្រួល និងផ្នែកណាដែលលំបាកបំពេញ ។ ទំរង់នេះត្រូវបានកែសម្រួលទៅតាមយោបល់អ្នកចូលរួម ។<br>/ ប្រមូលទំរង់ដែលអ្នកចូលរួមបានបំពេញ ដើម្បីប្រើនៅសកម្មភាពក្រោយ ។<br>/ ពិភាក្សាលើសំណួរមួយចំនួនបន្ថែមទៀត:<br>? បេក្ខជនទទួលពាក្យនិងដាក់ពាក្យនៅឯណា?<br>? អ្នកណាជាអ្នកទទួលខុសត្រូវ? អ្នណាជាអ្នកទទួលពាក្យ?<br>? ចាប់ទទួលថ្ងៃណា ? ឈប់ទទួលថ្ងៃណា?<br>**៣.៣.២. <u>ការបង្កើតបញ្ជីសង្ខេបលើកទី១</u>:** | អ្នកចូលរួមផ្តល់ចម្លើយ:<br>គេនឹងមកសាលាឃុំឬ............ សាកសួរដំណឹង បន្ថែម ហើយរកគំរូពាក្យសុំ ។<br><br><u>ការងារជាបុគ្គល</u>:<br>បំពេញទំរង់ពាក្យសុំ<br><u>ការងារជាដៃគូ</u>:<br>ពិនិត្យកិច្ចការរបស់ ដៃគូទៅវិញទៅមក ។<br><br>អ្នកចូលរួមផ្តល់ចម្លើយ ហើយសរសេរចម្លើយនោះនៅលើផ្ទាំងក្រដាសធំហើយបិទនៅលើក្តារខៀន ។<br><br>អ្នកចូលរួមគិតឡើងវិញលើ |

| | | |
|---|---|---|
| | / ពន្យល់ទៅក្រុមធំ៖ នៅពេលប្រមូលពាក្យសុំហើយ អ្នកមិនអាចសំភាសន៍ទាំងអស់គ្នាបានទេ អ្នកត្រូវពិនិត្យពាក្យសុំទាំងអស់នោះហើយ ជ្រើសយកពាក្យសុំណាដែលយល់ថា ត្រូវនឹងល័ក្ខខ័ណ្ឌបំផុតដើម្បីសំភាសន៍។ ធ្វើបែបនេះហៅថាការធ្វើបញ្ជីសង្ខេបលើកទី១។<br>/ សួរទៅក្រុមធំ៖ តើអ្នកណាជាអ្នកធ្វើបញ្ជីនេះ? តើធ្វើដូចម្តេច?<br>/ ចែកអ្នកចូលរួមជា៣ក្រុម។ក្រុមនិមួយៗបានទទួលពាក្យដែលបំពេញរួច មួយចំនួន និងទំរង់បញ្ជីសង្ខេបមួយសន្លឹក ។<br>/ បង្ហាញលទ្ធផលដល់ក្រុមធំ។<br>/ បូកសរុប។ ចំនួនបេក្ខជនក្នុងបញ្ជីសង្ខេបគួរមានឈ្មោះយ៉ាងតិចចំនួន២ដងនៃចំនួនគ្រូត្រូវជ្រើសរើស បើបាន៣ដងជាការល្អ។ | ចំនុច៣.១.៣.ការផ្តល់ទម្ងន់លើចំនុច និមួយៗក្នុងលក្ខណៈវិនិច្ឆ័យ៖<br><br>អ្នកចូលរួមឆ្លើយ (ផ្អែកតាមការសម្រេច របស់ក្រុមធំ។<br>ក្រុមនិមួយៗពិនិត្យពាក្យសុំនិងស្រង់ឈ្មោះធ្វើបញ្ជីសង្ខេប។<br>តំណាងក្រុមឡើងបកស្រាយនិងចែលរំលែកពីការលំបាកក្នុងការជ្រើសរើស។ |
| **ខ្លឹមសារ និងសេចក្តីសង្ខេប៖**<br><br>**រយៈពេល៖** | **៣.៤៖ ការសំភាសន៍៖** ផ្នែកនេះ ផ្តល់ឱកាសឱ្យអ្នកចូលរួមបានពិនិត្យនិងកែសម្រួលកំរងសំនួរសំភាសន៍ និងធ្វើការសំដែងតួ ជាអ្នកសំភាសន៍និងអ្នកត្រូវគេសំភាសន៍។<br>៦០នាទី | |
| **សម្ភារដែលត្រូវការ៖** | ○ ឯកសារចែកទី៦៖ កំរងសំណួរសំភាសន៍<br>○ ឯកសារចែកទី៧៖បញ្ជីឈ្មោះគ្រូសហគមន៍ដែលបានជ្រើសរើស | |
| **វត្ថុបំណង** | ***សកម្មភាពអ្នកសម្របសម្រួល*** | ***សកម្មភាពអ្នកចូលរួម*** |
| អ្នកចូលរួមអាចមានជំនាញក្នុងការសំភាសន៍ជ្រើសរើសគ្រូសហគមន៍។ | **៣.៤.១. <u>កំរងសំណួរ៖</u>**<br>/ សួរទៅក្រុមធំ៖<br>**?** តើអ្នកធ្លាប់ធ្វើជាអ្នកសំភាសន៍ឬត្រូវបានគេសំភាសន៍ឬទេ?<br>**?** តើគេប្រើឧបករណ៍អ្វី ក្នុងការសំភាសន៍?<br>/ ចែកឯកសារទី ៦ ដល់អ្នកចូលរួម។ អំណានស្ងាត់ រួចពិភាក្សានិងកែសម្រួលតាមយោបល់អ្នកចូលរួម។<br>**៣.៤.២. <u>ការសំដែងតួ៖</u>**<br>/ រកអ្នកស្ម័គ្រចិត្ត ៤ឬ៥នាក់ឡើងមកសំដែងតួ ជាគណៈកម្មការសំភាសន៍ និងបេក្ខជន។<br>/ ពិភាក្សាហេតុអ្វីការដាក់ពិន្ទុមានភាពខុសគ្នា។<br>/ ចែកកំរងសំណួរឱ្យអ្នកចូលរួមគ្រប់ៗគ្នា។<br>/ ឱ្យអ្នកចូលរួមហាត់សំភាសន៍ជាដៃគូ ដោយប្តូរវេនគ្នាសំភាសន៍ | អ្នកចូលរួមឆ្លើយ៖កំរងសំនួរ<br>អ្នកចូលរួមពិភាក្សាក្នុងក្រុមធំមួយសំនួរម្តងៗ។<br><br><br><br><br>អ្នកស្ម័គ្រចិត្តសំដែងតួ អ្នកឯទៀតជាអ្នកសង្កេត។<br>គណៈកម្មការ បូកសរុប ពិន្ទុនិងបង្ហាញលទ្ធផល។<br>សំណួរនិងចម្លើយ<br>អ្នកចូលរួមសួរសំនួរនិងពិភាក្សា |

| | | |
|---|---|---|
| | ដាក់ពិន្ទុលើកំរងសំណួរដែលចែកឱ្យ ។ ប្រៀបធៀបលទ្ធផលនិង<br>កំនត់ពិន្ទុដែលជាស្តង់ដាសមស្រប ។<br>/ ចែកឯកសារទី៧ និងពន្យល់ពីរបៀបបំពេញ ។<br>/ សួរថាៈ<br>? តើគណៈកម្មការសំភាសន៍ធ្វើអ្វីខ្លះ ក្រោយពីបានលទ្ធផល<br>ហើយ?<br>? តើអ្នកណាខ្លះ នឹងក្លាយជាគណៈកម្មការសំភាសន៍ពិតប្រាកដ?<br><br>ចាប់ផ្តើមឱ្យអ្នកចូលរួមគិតពីការបែងចែកការងារសំរាប់ដំណើរ<br>ការជ្រើសរើសគ្រូសហគមន៍ ថាតើៈ<br>១.ធ្វើ**អ្វីខ្លះ**?<br>២. **អ្នកណា**ទទួលខុសត្រូវ? អ្នកណាចូលរួម?<br>៣. ធ្វើ **ដូចម្តេច**?<br>៤. ធ្វើ**នៅពេលណា**?<br>៥. ធ្វើ**នៅឯណា**?<br>៦. ត្រូវការ**ធនធានអ្វី**ខ្លះ? | អ្នកចូលរួមផ្តល់ចម្លើយៈ<br>..........................................<br>បំពេញបញ្ជីឈ្មោះគ្រូសហគមន៍<br>ភ្ជាប់ជាមួយពាក្យសុំរបស់អ្នក<br>ជាប់ឈ្មោះ ហើយ បញ្ជូនទៅ<br>គណៈកម្មការកំរង ហើយ<br>គណៈកម្មការកំរងបញ្ជូនទៅ<br>ក្រុមការងារថ្នាក់ខេត្ត ។<br>ក្រោយពីមានការយល់ព្រមពី<br>ក្រុមការងារថ្នាក់ខេត្តហើយឱ្យ<br>គ្រូចុះកិច្ចសន្យា ។ |
| **ខ្លឹមសារ និងសេចក្តីសង្ខេបៈ**<br><br><br><br>**រយៈពេលៈ** | **៣.៤: ផែនការលំអិតសម្រាប់ដំណើរការជ្រើសរើសៈ** ផ្នែកនេះ អ្នកចូលរួមមានឱកាសពិភាក្សាតាមកំរង ដើម្បីបង្កើតកាលវិភាគជាក់ស្តែងតាមកំរងនិមួយៗ សំរាប់យកទៅអនុវត្ត ដើម្បីធានាក្នុងការជ្រើសរើស គ្រូសហគមន៍ តាមលំនាំដែលបានរៀនក្នុងវគ្គនេះ ហើយសម្រេចបានបញ្ជីឈ្មោះគ្រូសហគមន៍តាមពេល កំនត់ ។<br>៦០នាទី | |
| | | |
| *វត្ថុបំណង* | *សកម្មភាពអ្នកសម្របសម្រួល* | *សកម្មភាពអ្នកចូលរួម* |
| អ្នកចូលរួមអាចៈ<br>O បង្កើតផែនការលំអិត<br>សម្រាប់ដំណើរការ<br>ជ្រើសរើសគ្រូសហគមន៍<br><br>O កំនត់អ្នកទទួលខុសត្រូវ | O សួរទៅក្រុមធំៈ<br>? តើអ្នកធ្លាប់ធ្វើផែនការអ្វីខ្លះ?<br>? ហេតុអ្វី យើងចាំបាច់ត្រូវការធ្វើផែនការ?<br>? តើគួរមានចំនុចអ្វីខ្លះ នៅក្នុងផែនការ?<br>O ចែកតារាងផែនការឱ្យអ្នកចូលរួមម្នាក់មួយសន្លឹក ។<br>O សួរពួកគេថា តើធ្លាប់ប្រើតារាងបែបឬទេ? បើធ្លាប់ប្រើហើយ | អ្នកចូលរួមឆ្លើយៈ<br>- ផែនការអភិវឌ្ឍកំរងលាសា<br>-ផែនការអភិវឌ្ឍឃុំ...........<br>ផែនការអាចជួយយើងឱ្យដឹងថា<br>ធ្វើអ្វីខ្លះ អ្នកណាទទួលខុសត្រូវ<br>ធ្វើនៅពេលណា នៅឯណា<br>ត្រូវការធនធានអ្វីខ្លះ ។ ពេល |

| | | |
|---|---|---|
| លើសកម្មភាពនិមួយៗ ។ | អ្នកសម្រប សម្រួលមិនចាំបាច់ចំណាយពេលយូរក្នុងការពន្យល់ ។<br>O បិទតារាងផែនការ ដែលសរសេរលើផ្ទាំងក្រដាសធំ នៅលើក្ដារខៀន ដើម្បីឱ្យអ្នកចូលរួមបានឃើញទាំងអស់គ្នា ។ ពន្យល់ពីរបៀបសរសេរ ។<br>O កំរងនិមួយៗតាមក្រុមពិភាក្សាគ្នា ធ្វើផែនការ ។ ក្រុមត្រូវគិតដល់ធនធាន ដែលត្រូវការផងដែរ សម្រាប់សកម្មភាពនិមួយៗ ហើយសរសេរនៅលើតារាងមួយសិន ។ពេលដែលយល់ថាត្រឹមត្រូវហើយ ទើបនាំគ្នាចម្លងចូលតារាង ម្នាក់មួយ ។<br>O អ្នកសម្របសម្រួលដើរជួយតាមក្រុម ។<br>O បូកសរុប ។ បញ្ជាក់ថា នេះជាផែន ការជាក់ស្ដែង ដែលកំរងត្រូវយកទៅប្រើក្នុងការជ្រើសរើសគ្រូសហគមន៍នៅសប្ដាហ៍ខាងមុខ ។ | យើងបិទផែនការនោះនៅកន្លែងណា ដែលគ្រប់គ្នាមើលឃើញ ។ គេនឹងមានការទទួលខុសត្រូវចំពោះអ្វីដែលគេត្រូវធ្វើ ។ |
| **ខ្លឹមសារ និងសេចក្ដីសង្ខេបៈ**<br><br>**រយៈពេលៈ** | **៣.៥ៈ ជំហានបន្ទាប់ ៈ**<br>៦០នាទី | |
| **សម្ភារដែលត្រូវការៈ** | ○ ផ្ទាំងក្រដាសធំៈ លក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសគ្រូសហគមន៍<br>○ ឯកសារចែកៈ លក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសគ្រូសហគមន៍ | |
| *វត្ថុបំណង* | *សកម្មភាពអ្នកសម្របសម្រួល* | *សកម្មភាពអ្នកចូលរួម* |
| អ្នកចូលរួមអាចរៀបរាប់ចំនុចដែលត្រូវធ្វើ នៅពេល ត្រលប់ទៅសាលា និង ទៅសហគមន៍វិញ ។ | O ចាប់ផ្ដើមដោយរំលឹកអ្នកចូលរួមថា ដំណើរការនេះ មិនមែន ត្រូវចប់នៅក្នុងសិក្ខាសាលានេះទេ ។ អ្នកនឹងត្រូវប្រើផែនការរបស់អ្នក ដើម្បីនាំផ្លូវអ្នកក្នុងការជ្រើសរើសគ្រូសហគមន៍ ។<br>O បិទប៉ុស្ទ័រដែលសង្ខេបអំពីសកម្មភាពជំហានបន្ទាប់ ដែលត្រូវធ្វើដើម្បីសម្រេចឱ្យបានបញ្ជីឈ្មោះគ្រូសហគមន៍ ដើម្បីផ្ញើជូនទៅក្រុមការងារថ្នាក់ខេត្ត តាមកាលកំនត់ ។<br><u>សកម្មភាពក្នុងជំហានបន្ទាប់ទៅទៀតនេះ រួមមានៈ</u><br>● បើកប្រាក់បុរេប្រទាន ដើម្បីប្រតិបត្តិការងារ ។<br>● ប្រជុំថ្នាក់ភូមិ /ឃុំ ដើម្បីផ្សព្វផ្សាយពីការជ្រើសរើសគ្រូសហគមន៍ ( ប្រសិនបើកំរងយល់ថាត្រូវធ្វើ) ។<br>● ធ្វើទំនាក់ទំនងជាមួយវត្តអារាម ជាមួយព្រះសង្ឃ | អ្នកចូលរួមផ្ដល់ចម្លើយ ។<br>អ្នកចូលរួមអានឯកសារទី១០ និងសួរសំណួរ ។ |

| | | |
|---|---|---|
| | និងអាចារ្យវត្ត ។<br>● *ធ្វើទំនាក់ទំនងជាមួយវិហារឥស្លាមនិងអ៊ីម៉ាំ (IMAM) (ចំពោះកំរងដែលមានជនជាតិឥស្លាមច្រើន) ។*<br>● *ធ្វើទំនាក់ទំនងជាមួយចាស់ទុំក្នុងភូមិ ឬមេភូមិ ចំពោះកំរងដែល មានជណជាតិភាគតិច ។*<br>● ផ្សាយដំណឹងជ្រើសរើស ។<br>● ទទួលពាក្យនិងប្រមូលពាក្យសុំបំរើការងារ ។<br>● ធ្វើបញ្ជីឈ្មោះបេក្ខជនសរុប ដែលបានដាក់ពាក្យសុំ បំរើការងារ ។<br>● ធ្វើបញ្ជីសង្ខេបលើកទី១ ។<br>● កំនត់ថ្ងៃ ដើម្បីអញ្ជើញបេក្ខជនមកសំភាសន៍ ។<br>● រៀបចំទំរង់ទាំងអស់ដែលត្រូវប្រើ ។<br>● ធ្វើការសំភាសន៍បេក្ខជនដែលជាប់ឈ្មោះក្នុងបញ្ជីសង្ខេប ។<br>● គណៈកម្មការជ្រើសរើស ធ្វើការបូកសរុបពិន្ទុនិងជ្រើសរើសបេក្ខជន ។<br>● ស្រង់ឈ្មោះអ្នកជាប់ ហើយបញ្ជូនបញ្ជីឈ្មោះគ្រូសហគមន៍ដែលបានជ្រើសរើសទៅក្រុមការងារថ្នាក់ខេត្ត (ភ្ជាប់ជាមួយនូវពាក្យសុំ របស់បេក្ខជនដែលជាប់ ហើយរក្សាទុកឯកសារផ្សេង១ទៀតទាក់ នឹងការការជ្រើសរើសនៅកំរងសាលា រួមមាន ដូចជាពាក្យសុំនិង លទ្ធផលសំភាសន៍របស់បេក្ខជនដែលបានដាក់ពាក្យ ទាំងអស់ជា ដីម ។<br>● ទូទាត់ប្រាក់បុរេប្រទាន ។<br>● ផ្តល់ព័ត៌មានដល់គ្រូសហគមន៍ អំពីថ្ងៃបើកវគ្គបំប៉ន ដែលអេស្កាប់នឹងបើក ។ ត្រៀមអញ្ជើញពួកគេឱ្យចូលរៀន ក្នុងវគ្គនោះ ។<br>o ទុកឱកាសឱ្យអ្នកចូលរួមទាំងអស់សួរសំណួរ ហើយបកស្រាយក្នុងករណីចាំបាច់ ។ | |

## APPENDICES


| Handout No. | Content | Page |
|---|---|---|
| 1 | Program Goal structure and interventions<br>គោលបំណងរចនាសម្ព័ន្ធ និង អន្តរាគមន៍ជាក់ស្តែងនៃកម្មវិធី | 2 |
| 2 | Concept of Child Friendly School<br>សាលាកុមារមេត្រី | 3 |
| 3 | Criteria for Community Teacher selection<br>លក្ខណៈវិនិច្ឆ័យក្នុងការជ្រើសរើសគ្រូសហគមន៍ | 5 |
| 4 | Advertisement<br>សេចក្តីជូនដំណឹង | 6 |
| 5 | Application form<br>ពាក្យសុំចូលបំរើការងារជាគ្រូសហគមន៍ | 7 |
| 6 | Format: list of Candidates to be interviewed<br>បញ្ជីបេក្ខជនដែលត្រូវសំភាសន៍ដើម្បីធ្វើជាគ្រូសហគមន៍ | 8 |
| 7 | Interview questionnaire<br>កំរងសំណួរសំភាសន៍គ្រូសហគមន | 9 |
| 8 | Format: list of selected candidates<br>បញ្ជីឈ្មោះគ្រូសហគមន៍ដែលបានជ្រើសរើស | 11 |
| 9 | Community teacher Contract<br>កិច្ចសន្យាការងារ | 12 |
| 10 | Next Step<br>សកម្មភាពក្នុងជំហានបន្ទាប់ ក្នុងការជ្រើសរើសគ្រូសហគមន៍ | 14 |
| 11 | Implementation plan<br>តារាងផែនការជ្រើសរើសគ្រូសហគមន៍ | 15 |

# គោលបំណងរចនាសម្ព័ន្ធ និង អន្តរាគមន៍ជាក់ស្តែងនៃកម្មវិធី

**១- គោលបំណងរបស់កម្មវិធី :**

- O បង្កើនភាពងាយស្រួលចូលសាលារៀន និងគុណភាពការអប់រំមូលដ្ឋាន សម្រាប់ក្រុម គោលដៅដែលមិនសូវបានទទួលសេវាអប់រំ ជាពិសេស *កុមារក្រីក្រ កុមារពិការ កុមារី និងកុមារជនជាតិភាគតិច ។*
- O *គាំទ្រសិទ្ធិកុមារ* តាមរយៈកម្មវិធីសាលាកុមារមេត្រី ដែលបានរៀបចំដោយ ក្រសួងអប់រំ យុវជន និងកីឡា។

**២- អន្តរាគមន៍ជាក់ស្តែង :**

- O កម្មវិធីអេស្កាប់ផ្តោតលើ៣ផ្នែកសំខាន់ៗ *គឺ (១) ការបំប៉នគ្រូ (២) ភាពងាយស្រួលចូលសាលារៀន និងគុណភាពអប់រំ (៣) ការសហការរវាងសាលារៀន និងសហគមន៍ ។*
- O អន្តរគមន៍នីមួយៗស្ថិតនៅក្នុងផ្នែកធំៗទាំងបី ដូចខាងក្រោម :

| **ការបំប៉នគ្រូ** | **ភាពងាយស្រួលចូលសាលារៀន និងគុណភាពអប់រំ** | **ការសហការរវាងសាលារៀន និងសហគមន៍** |
|---|---|---|
| 1. អាហារូបករណ៍គរុសិស្ស 12+2 ឬ 9+2 ដែលមកពីមូលដ្ឋានទីតាំងគោលដៅ<br>2. ការបំប៉នគ្រូសហគមន៍<br>3. ការគាំទ្របច្ចេកទេសដល់គ្រូដាច់ស្រយាល<br>4. ការបំប៉នគ្រូសម្រាប់កម្មវិធីកុមារតូច | 5. អាហារូបករណ៍សិស្សក្រីក្រនៅបឋមសិក្សា<br>6. អាហារូបករណ៍សសិស្សក្រីក្រអនុវិទ្យាល័យ<br>7. ការបំប៉នសិស្សខ្សោយ<br>8. ការគាំទ្រការប្រតិបត្តិកម្មវិធីកុមារតូច ក្នុងថ្នាក់រៀន ( ផ្តល់សម្ភារឬ ឯកសារ ជាដើម )<br>9. បំណិនជីវិតផ្សេងៗ<br>10. ការកែលំអហេដ្ឋានរចនាសម្ព័ន្ធ<br>11. ជំនួយផ្នែករាងកាយសម្រាប់សិស្ស ពិការ<br>12. បណ្តាញកុមារជួយកុមារ | 13. បំណិនជីវិតទាក់ទងនឹងវប្បធម៌<br>14. បង្កើតមណ្ឌលវប្បធម៌<br>15. បង្កើតសមាគមយុវជនជនជាតិ<br>16. អ្នកជួយគ្រូចេះ ២ ភាសា<br>17. ការរៀនភាសាខ្មែរបន្ថែមសម្រាប់កុមារជនជាតិ<br>18. សិក្ខាសាលាកំនត់កុមារដែលមិនបានចូលរៀន<br>19. ការគ្រប់គ្រងគ្រូសហគមន៍ |

**៣- របៀបធ្វើការងាររបស់កម្មវិធីអេស្កាប់ :**

កម្មវិធិអេស្កាប់ ធ្វើការងារដោយផ្អែកតាមយុទ្ធវិធី៤យ៉ាងៈ

១- យុទ្ធវិធីដែលផ្អែកទៅលើសិទ្ធិកុមារ

២- សេរីភាពក្នុងរចនាសម្ព័ន្ធ

៣- ការប្រើប្រាស់អំណោយដោយមូលដ្ឋាន

៤- ការប្រតិបត្តិកម្មវិធីតាមរយៈគណៈកម្មការមូលដ្ឋា។

## សាលាកុមារមេត្រី

HO. 2



**ចំរៀក1/2 :**

យើងមានទីធ្លាសាលារៀនស្អាតប្រកបដោយសុវត្ថិភាព និង មានទឹកស្អាត............................

សំរាប់ហូប និង លាងដៃ ។

**ចំរៀក3/4 :**

សិស្សមានសុខភាពល្អនិងរក្សាសុខភាព.........................................

ដោយលេងកីឡាផ្សេងៗ ។

**ចំរៀក5/6 :**

កុមារទាំងអស់នៅក្នុងសហគមន៏អាចទៅ......................................

រៀនប្រកបដោយសុវត្ថិភាព ដោយមិនគិតអំពីភេទ ពិការភាព ឬក៏ភាសាដែលគេនិយាយ ។

**ចំរៀក7/8 :**

ទីកន្លែងដែលកុមាររៀន ជា ................................................

កន្លែងដែលធ្វើអោយគេសប្បាយរីករាយ ។ កុមារចូលចិត្តទៅសាលារៀន ពីព្រោះមាន សកម្មភាពគួរឱ្យចាប់អារម្មណ៏ទាំងក្នុងថ្នាក់ និង ក្រៅថ្នាក់រៀន ។

**ចំរៀក9/10 :**

គ្រូទាំងអស់នៅតាមសាលារៀនបង្ហាញគំរូល្អដល់ ......................................................

កុមារា និង កុមារី ។

**ចំរៀក11/12 :**

ឪពុកម្តាយ និង ក្រុមគ្រួសារ........................

ជាផ្នែកមួយនៃការសិក្សារបស់កូន ។

**ចំរៀក13/14 :**

យើងឱ្យឪពុកម្តាយនិងក្រុមគ្រួសារយើងចូលរួមក្នុង......................................................

សកម្មភាពរៀនសូត្រប្រចាំថ្ងៃរបស់យើងហើយយើងអញ្ជើញគាត់ចូលរួមក្នុងព្រឹត្តិការណ៏សំខាន់ៗរបស់សាលាយើង។

**ចំរៀក15/16 :**

កុមារី និង កុមារា មានឱកាសស្មើគ្នាក្នុងការចូលរៀននិងនៅរៀនបន្តឱ្យចប់...................................

យ៉ាងហោចណាស់ដល់ថ្នាក់ទី៩ ។

**ចំរៀក17/18 :**

កុមារចាប់ពីអាយុ ៦ ឆ្នាំ ទាំងអស់ ត្រូវ ....................................................................

ទៅសាលារៀន ។

**ចំរៀក19/20 :**

ការអប់រំដែលកុមារទទួលបានត្រូវ ..........................................................................

សមស្របទៅនឹងបរិស្ថានដែលគេរស់នៅ ។

**ចំរៀក20/21 :**

សាលាមិនរង់ចាំកុមារ.................................................................................................

មកចុះឈ្មោះចូលរៀនទេ តែសាលាធ្វើការស្រាវជ្រាវ ដើម្បីរកកុមារដែលគ្រប់អាយុចូលរៀន ។

**ចំរៀក22/23 :**

កាបង្រៀនរបស់គ្រូ ទាក់ទាញឱ្យ.......................................................................

សិស្សមានចិត្តចង់រៀន ដោយពួកគេបានបញ្ចេញយោបល់និងធ្វើសកម្មភាពតាមក្រុមជួយគ្នាទៅវិញទៅមក ។

**សំណួរ និង ចម្លើយអំពីបញ្ញត្តិសាលាកុមារមេត្រី:**

ក) តើអ្វីទៅ "សាលាកុមារមេត្រី" ?

ខ) បើនិយាយពីសាលាកុមារមេត្រី គឺត្រូវនិយាយពីសិទ្ធិ៤យ៉ាងរបស់កុមារ ។

តើសិទ្ធិ៤យ៉ាងនោះ គឺអ្វីខ្លះ?

គ) ឥឡូវនេះ យើងនិយាយពីសិទ្ធិក្នុងការអភិវឌ្ឍ? តើមានន័យដូចម្តេច?

ឃ) តើ ធ្វើដូចម្តេចទើបសម្រេចបាន?

(មើលចម្រៀកប័ណ្ណឃ្លាទាំងអស់លើក្តារខៀន ដែលបានរៀបតាមប្រភេទ ក្នុងសកម្មភាពមុន)

**ចម្លើយគ្រោងទុក :**

ក) កាលណាយើងនិយាយពីសាលាកុមារមេត្រី គឺយើងនិយាយអំពីសិទ្ធិធំ១៤យ៉ាងរបស់កុមារ ។

ខ) សិទ្ធិក្នុងការអភិវឌ្ឍ សិទ្ធិរស់រានមានជីវិត សិទ្ធិក្នុងការការពារ និងសិទ្ធិក្នុងការចូលរួម ។

គ) យើងនិយាយពីសិទ្ធិក្នុងការអភិវឌ្ឍគឺការជួយកុមារឱ្យរៀនបានល្អ ។

ឃ) កត្តាដែលធ្វើឱ្យសាលារៀនក្លាយជាសាលាកុមារមេត្រី :

1. ការអប់រំស្មើភាពនិងមិនប្រកាន់
2. ការរៀនសូត្រប្រកបដោយប្រសិទ្ធភាពនិងទំនាក់ទំនងជាមួយជីវិតរស់នៅប្រចាំថ្ងៃ
3. បរិស្ថានគាំទ្រសុខភាពនិងសុវត្ថភាព
4. ការអប់រំយេនឌ័រ
5. ការចូលរួមរបស់មាតាបិតាសិស្សនិងភាពជាមួយសហគមន៍

**HO. 3**

# លក្ខណៈវិនិច្ឆ័យក្នុងការជ្រើសរើសគ្រូសហគមន៍

| ល.រ. | *ទម្ងន់លើចំនុចនិមួយៗដែលគណៈកម្មការសម្រេចកំនត់ ក្នុងការបង្កើតបញ្ជីឈ្មោះអ្នកត្រូវសំភាសន៍* | | | |
|---|---|---|---|---|
| | **លក្ខណៈវិនិច្ឆ័យ** | ● | ●● | ●●● |
| ១ | យ៉ាងហោចណាស់ ជាអតីតសិស្សរៀនចប់ថ្នាក់ទី ៩ ឬ ថ្នាក់ប្រហាក់ប្រហែល *( ស្រុកអូររាំងនិងកែវសីមា នៅខេត្តមណ្ឌលគីរី អាចក៏រិតទាបជាងថ្នាក់ទី៩)* | | | |
| ២ | ជាអ្នករស់នៅក្នុងភូមិ ដែលចំណុះឱ្យសាលា | | | |
| ៣ | ចេះភាសាពីរគឺភាសាខ្មែរ និងភាសាជនជាតិណាមួយ ដែលមានកុមារជនជាតិរៀននៅសាលានោះ ( សម្រាប់តំបន់ដែលមានកុមារជនជាតិ) | | | |
| ៤ | ធ្លាប់មានបទពិសោធន៏ការងារអភិវឌ្ឍសហគមន | | | |
| ៥ | ធ្លាប់មានបទពិសោធន៏ក្នុងការបង្រៀន | | | |
| ៦ | មានចរិយាល្អនិងទទួលការរាប់អានពីអ្នកភូមិ | | | |
| ៧ | ចូលចិត្តរៀនសូត្រអ្វីដែលថ្មី | | | |
| ៨ | មានការតាំងចិត្ត បំរើការងារក្នុងរយៈពេល២ឆ្នាំ | | | |
| ៩ | មានសុខភាពល្អ | | | |
| ១០ | បេក្ខជនជានារី | | | |

*<u>សំគាល់:</u> មានលក្ខណៈសម្បត្តិមួយចំនួនទៀត ដែលនឹងត្រូវបញ្ចូលនៅក្នុងការសំភាសន៏ផ្ទាល់មាត់ ដូចជា:*

- ❑ *មានភាពវាងវៃក្នុងការងារ*
- ❑ *មានចិត្តស្រឡាញ់កុមារ*
- ❑ *ស្មោះត្រង់ចំពោះការងារ*
- ❑ *មានការព្យាយាមធ្វើការងារ សិក្សាស្រាវជ្រាវនិងរៀនសូត្រពីអ្នកដែលមានបទពិសោធន៏ ។*
- ❑ *ចេះបត់បែននិងច្នៃប្រឌិត*
- ❑ *មានទំនាក់ទំនងល្អនៅក្នុងភូមិ ។*

**HO. 4**

# សេចក្តីជូនដំណឹង

ដោយមានការយល់ព្រមពីក្រសួងអប់រំយុវជន និង កីឡា មន្ទីរអប់រំខេត្ត និងការិយាល័យអប់រំស្រុក កម្មវិធីអេស្កាប់( កម្មវិធីគាំទ្រការអប់រំដល់កុមារនៅតំបន់ដាច់ស្រយាល) រួមជាមួយកំរងសាលាមូលដ្ឋាន និងគណៈកម្មាធិការអប់រំសំរាប់ទាំងអស់គ្នាថ្នាក់ឃុំ ក្នុងឃុំ,,...................... .....សូមប្រកាសជ្រើសរើសបេក្ខជនដាក់ពាក្យធ្វើជាគ្រូសហគមន៍ ដែលត្រូវបង្រៀនរយៈពេល២ឆ្នាំ នៅសាលាបឋមសិក្សា ........................... ...................... ក្នុងកំរង............................................. ចាប់ពីឆ្នាំសិក្សា ២០០៥-២០០៦ នេះទៅ ។

<u>លក្ខណៈសម្បត្តិជ្រើសរើសមានដូចខាងក្រោមៈ</u>

- យ៉ាងហោចណាស់ ជាអតីតសិស្សរៀនចប់ថ្នាក់ទី ៩ ឬ ថ្នាក់ប្រហាក់ប្រហែល
  *( ដោយឡែក ចំពោះស្រុកអូររាំងនិងកែវសីមា នៅខេត្តមណ្ឌលគិរី អាចកំរិតទាបជាងថ្នាក់ទី៩)*
- ជាអ្នករស់នៅក្នុងភូមិ ដែលចំណុះឱ្យសាលា
- ចេះភាសាពីរគឺភាសាខ្មែរនិងភាសាជនជាតិណាមួយដែលមានកុមារជនជាតិរៀននៅសាលានោះ
- ជាមនុស្សដែលមានចរិយាល្អនិងទទួលការរាប់អានពីអ្នកភូមិ
- ចូលចិត្តរៀនសូត្រអ្វីដែលថ្មី
- មានការតាំងចិត្ត បំរើការងារក្នុងរយៈពេល២ឆ្នាំ
- មានសុខភាពល្អ
- មានអាយុចាប់ពី១៨ឆ្នាំឡើងទៅ

បើបងប្អូនណាមានការចាប់អារម្មណ៍ សូមមកទាក់ទងសាកសួរព័ត៌មានបន្ថែម និងទទួលពាក្យសុំបំរើការងារដែលមានចែកជូនដោយឥតគិតថ្លៃ នៅ................................................... រាល់ម៉ោងធ្វើការ ចាប់ពី ថ្ងៃទី,,........... ខែ,,....................... ឆ្នាំ២០០៥ នេះតទៅ ។

**ចាប់ទទួលពាក្យ ពីថ្ងៃទី,,..................ខែ,,................ ឆ្នាំ ២០០៥**

**ផុតកំនត់ទទួលពាក្យនៅថ្ងៃទី,,........... ខែ,,................ ឆ្នាំ ២០០៥ ។**

*មានតែបេក្ខជនដែលត្រូវជាប់ក្នុងបញ្ជីសង្ខេបលើកទី១ទេ ដែលត្រូវអញ្ជើញមកធ្វើការសំភាសន៍ ។*

*ទំនាក់ទំនងបន្ថែមតាមការិយាល័យទទួលពាក្យ ឬតាមទូរស័ព្ទ លេខ : ...........................*

*<u>បញ្ជាក់:</u> គ្រូសហគមន៍ដែលជាប់បំរើការងារជាមួយកម្មវិធីអេស្កាប់ នឹងបានទទួលប្រាក់ឧបត្ថម្ភ ចំនួន ១៨ដុល្លាក្នុង១ខែ ហើយគិត៩ខែក្នុង១ឆ្នាំសិក្សា ។*

**សូមអរគុណ**

**HO. 5**

# ពាក្យសុំចូលបំរើការងារជាគ្រូសហគមន៍

**១. ព័តិមានទូទៅ:**

នាងខ្ញុំ / ខ្ញុំបាទ ឈ្មោះ ------------------------ ភេទ --------- អាយុ -------------

សញ្ជាតិ ------------ សាសនា ---------------- ស្ថានភាពសុខភាព: ----------------

ស្ថានភាពគ្រួសារ ☐នៅលីវ ☐រៀបការ ☐ពោះម៉ាយ / មេម៉ាយ

មានកូនក្នុងបន្ទុក ☐មាន( ចំនួន-----------នាក់) ☐គ្មាន

មុខរបរសព្វថ្ងៃ: -------------------------------------------------------------------

ទីលំនៅសព្វថ្ងៃ: ភូមិ--------------ឃុំ--------------ស្រុក -----------ខេត្ត -----------------

មានបំនងប្តូរទីលំនៅ: ☐មាន ( ពេលណា?------------) ☐គ្មាន ☐មិនទាន់ដឹង

**២. កំរិតវប្បធមិទូទៅ:**

ថ្នាក់ចុងក្រោយបង្អស់:------------------- ឆ្នាំដែលឈប់រៀន: -----------

ចំណេះដឹងផ្នែកភាសាជនជាតិ ក្រៅពីភាសាខ្មែរ: ☐មាន *( បើមាន សូមបញ្ជាក់ក្នុងតារាងខាងក្រោម)* ☐គ្មាន

| ភាសា | និយាយ | | | | សរសេរ | | | | អាន | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ល្អ | ល្អង្គួរ | មធ្យម | ខ្សោយ | ល្អ | ល្អបង្គួរ | មធ្យម | ខ្សោយ | ល្អ | ល្អបង្គួរ | មធ្យម | ខ្សោយ |
| ........................ | | | | | | | | | | | | |
| ........................ | | | | | | | | | | | | |

**៣. ជំនាញផ្សេងៗដែលមាន:** ☐មាន ☐គ្មាន បើមានសូមបញ្ជាក់:

☐ភ្លេងបុរាណ ☐កាត់សក់ ☐ កាត់ដេរ ☐តុបតែងសំអាងការ ☐ជួសជុលកង់ ☐ជួសជុលម៉ូតូ

☐សិប្បកម្ម /ផ្សេងៗ( សូមបញ្ជាក់ ) :--------------------------------------------------

**៤. បទពិសោធន៏ការងារ:** ☐មាន ☐គ្មាន

បើមានសូមបញ្ជាក់ ( ធ្វើអ្វី នៅឆ្នាំណា អ្នកណាដឹងឮ) : ------------------------------------------

---------------------------------------------------------------------------------

**បានឃើញ និង បញ្ជាក់ថាឈ្មោះខាងលើនេះ** ធ្វើនៅ__________ ថ្ងៃទី_____ ខែ _______ឆ្នាំ _____

**ពិតជាមានទីលំនៅក្នុងភូមិ ឃុំ ស្រុក ខាងលើពិតមែន។** ហត្ថលេខា និងឈ្មោះ

**ធ្វើនៅ__________ ថ្ងៃទី_____ ខែ _______ឆ្នាំ _____**

**ហត្ថលេខា និង ឈ្មោះប្រធានភូមិ-----------------**

**ក្រសួង:..........................................** **HO. 6**

**ភូមិ:..........................................** **ឃុំ:..........................................**

# បញ្ជីបេក្ខជន
## ដែលត្រូវសំភាសន៍ដើម្បីធ្វើជាគ្រូសហគមន៍

| លរ. | ឈ្មោះ | ភេទ | អាយុ | ទីលំនៅ | ផ្សេងៗ |
|---|---|---|---|---|---|
| ១ | | | | | |
| ២ | | | | | |
| ៣ | | | | | |
| ៤ | | | | | |
| ៥ | | | | | |
| ៦ | | | | | |
| ៧ | | | | | |
| ៨ | | | | | |
| ៩ | | | | | |
| ១០ | | | | | |
| ១១ | | | | | |
| ១២ | | | | | |
| ១៣ | | | | | |
| ១៤ | | | | | |
| ១៥ | | | | | |

ចំនួនបេក្ខជនដែលបានជ្រើសរើសសំភាសន៍ :..........................នាក់ ស្រី:...................នាក់

ធ្វើនៅ................................ថ្ងៃទី..........ខែ...........................ឆ្នាំ២០០៥

ហត្ថលេខា

ជ. គណៈកម្មការជ្រើសរើស

ឈ្មោះ------------------------------..

# កំរងសំណួរសំភាសន៍គ្រូសហគមន៍

## (រយៈពេល ៥០នាទី សម្រាប់បេក្ខជនម្នាក់)

ឈ្មោះបេក្ខជនៈ .......................................................... កាលបរិច្ឆេទៈ..........................

ឈ្មោះអ្នកសំភាសន៍ៈ ..................................................... ម៉ោងៈ......................................

*សំគាល់ៈ* ***4:*** *ល្អណាស់* *3: ល្អ* *2: មធ្យម* *1: ក្រោមមធ្យម*

*មុនពេលចាប់ផ្តើមសួរសំណួរ អ្នកសំភាសន៏គួរណែនាំខ្លួន ហើយសួរបេក្ខជនថា តើគេបានដឹងអ្វីខ្លះពីកម្មវិធីអេស្កាប់ ។ គួរឆ្លៀតពេល ប្រមាណ៣-៥ នាទី ពន្យល់ពីកម្មវិធីអេស្កាប់ឱ្យបេក្ខជនបានដឹង ។*

| សំណួរ | | ពិន្ទុ | | | |
|---|---|---|---|---|---|
| | | 1 | 2 | 3 | 4 |
| **ចំណាប់អារម្មណ៍ទូទៅ *(10នាទី)*** | | | | | |
| ១ | តើអ្វីទៅដែលទាក់ទាញអ្នក ឱ្យចាប់អារម្មណ៍ចង់ធ្វើជាគ្រូសហគមន៏ ? | | | | |
| ២ | តើអ្វីខ្លះទៅដែលជាបញ្ហាចំបងៗ ទាក់ទងទៅនឹងការអប់រំកុមារ នៅក្នុងមូលដ្ឋានភូមិឃុំរបស់អ្នក? | | | | |
| ៣ | តើអ្នកយល់ថាកុមារក្រីក្រ កុមារី កុមារជនជាតិ និងកុមារពិការ គួរតែមានឱកាសបានរៀនសូត្រដូចកុមារឯទៀតៗដែរឬទេ? ហេតុអ្វី? | | | | |
| ៤ | តើអ្នកយល់ថាគួរធ្វើយ៉ាងណា ដើម្បីឱ្យកុមារគ្រប់ៗរូបដែលគ្រប់អាយុ បានចូលរៀន ហើយនៅរៀនបន្តរហូតចូលវិទ្យាល័យ? | | | | |
| **បទពិសោធន៏ការងារ *(20នាទី)*** | | | | | |
| ៥ | តើអ្នកកំពុងប្រកបមុខរបរអ្វី សព្វថ្ងៃនេះ?<br>(បើមាន តើអ្នកលៃពេលវេលាដូចម្តេច រវាងការងារបច្ចុប្បន្ន និង ការបង្រៀន?) | | | | |
| ៦ | តើអ្នកគិតថា អ្នកមានចំនេះដឹង ជំនាញ ឬ បទពិសោធន៏អ្វីខ្លះ ដែលរួមចំនែកជួយដល់ការបង្រៀនរបស់អ្នក? | | | | |
| ៧ | តើអ្នកធ្លាប់បានបង្រៀនកុមារដែរឬទេ?បើធ្លាប់ តើបង្រៀននៅឯណា? ប្រើវិធីសាស្រ្តអ្វី? | | | | |

| | | | | | |
|---|---|---|---|---|---|
| | | | | | |
| ៨ | តាមការយល់ឃើញរបស់អ្នក តើគ្រូគួរធ្វើដូចម្តេច ដើម្បីបង្រៀនកុមារឱ្យឆាប់យល់? | | | | |
| ៩ | តើអ្នកយល់ថាគួរធ្វើដូចម្តេចឱ្យកុមារជនជាតិ ដែលចេះភាសាខ្មែរតិចតួច មានចិត្តចង់រៀន? | | | | |
| **បុគ្គលិកលក្ខណៈ /អាកប្បកិរិយា *(10នាទី)*** | | | | | |
| ១០ | តើអ្នកយល់ថា វិធីណាខ្លះដែលអាចជួយរូបអ្នកឱ្យក្លាយជាគ្រូល្អបាន? | | | | |
| ១១ | តើអ្នកធ្វើដូចម្តេចនៅពេលបង្រៀន បើសិស្សសួរសំណួរមួយដែលអ្នកនឹកមិនឃើញហើយឆ្លើយមិនបាន? | | | | |
| ១២ | បើយើងជួបអ្នកភូមិណាម្នាក់ដែលស្គាល់អ្នកជិតស្និទ្ធ ហើយសួរគាត់អំពីរូបអ្នក តើអ្នកគិតថាគាត់នឹងនិយាយប្រាប់យើងដូចម្តេចខ្លះ? | | | | |
| ១៣ | តើទៅអនាគត អ្នកមានផែនការចង់ធ្វើអ្វី? | | | | |
| **សំនួរផ្សេងទៀតដែលគណៈកម្មការសំភាសន៍អាចសួរ*(5នាទី)*** <br>• តើអ្នកយល់យ៉ាងណាចំពោះប្រាក់ខែ ដែលកំនត់? <br>• បើយើងត្រូវការប្រវត្តិរូបសង្ខេបរបស់អ្នក តើអាចផ្តល់ឱ្យយើងបានឬទេ? <br>• តើអ្នកមានសំណួរអ្វីចង់សួរយើងវិញឬទេ? | | | | | |
| *ពិន្ទុសរុប* | | | | | |

**លទ្ធផលនៃការសំភាសន៍ ( យោបល់រួម):**

**HO. 8**

**កំរង:**.......................................................

**ភូមិ:**.........................................          **ឃុំ:**...........................................

## បញ្ជីឈ្មោះគ្រួសហគមន៍ដែលបានជ្រើសរើស

| លរ. | ឈ្មោះ | ភេទ | អាយុ | ទីលំនៅ | ផ្សេងៗ |
|---|---|---|---|---|---|
| ១ | | | | | |
| ២ | | | | | |
| ៣ | | | | | |
| ៤ | | | | | |
| ៥ | | | | | |
| ៦ | | | | | |
| ៧ | | | | | |
| ៨ | | | | | |
| ៩ | | | | | |
| ១០ | | | | | |
| ១១ | | | | | |
| ១២ | | | | | |
| ១៣ | | | | | |
| ១៤ | | | | | |
| ១៥ | | | | | |

ចំនួនបេក្ខជនដែលបានជ្រើសរើសជាគ្រូសហគមន៍ :..........................នាក់ ស្រី:....................នាក់

ធ្វើនៅ.................................ថ្ងៃទី...........ខែ............................ឆ្នាំ២០០៥

ឈ្មោះនិងហត្ថលេខាគណៈកម្មការជ្រើសរើស

១-.........................................................................

២-.........................................................................

៣-.........................................................................

៤-.........................................................................

**World Education, Inc.**
No. 37 Street 105, Sangat Boeung Prolit, Khan 7 Makara
PO Box 74, Phnom Penh, Cambodia
Tel: (855-23) 216-854; email: worldedcam@online.com.kh
& kurtb.worlded@online.com.kh

# កិច្ចសន្យាការងារ

លោក /លោកស្រី.......................................

កម្មវិធីអេស្កាប់ មានសេចក្តីរីករាយនឹងធ្វើកិច្ចសន្យាជាមួយលោក, អ្នក ធ្វើជាគ្រូសហគមន៍ក្នុងកម្មវិធីអេស្កាប់នៅខេត្ត..........................ដែលមានប្រសិទ្ធភាពចាប់ពី ដើម ខែ វិច្ឆិកា ឆ្នាំ២០០៥ រហូតដល់ ដំណាច់ខែកក្កដា ឆ្នាំ ២០០៧ ក្រោមល័ក្ខខ័ណ្ឌ ការងារដូចខាងក្រោម ។សូមអានល័ក្ខខ័ណ្ឌ កិច្ចសន្យា របស់លោក, អ្នក ដោយប្រុងប្រយ័ត្ន ប្រសិនបើលោក, អ្នកយល់ព្រមគោរពតាមល័ក្ខខ័ណ្ឌការងារទាំងនេះ សូមចុះហត្ថលេខា និងបរិច្ឆេទ លើទំព័រខាងក្រោយបង្អស់នៃកិច្ចសន្យា ។

## ល័ក្ខខ័ណ្ឌការងារ

**ក-ទីកន្លែង ម៉ោងធ្វើការ និង ការគ្រប់គ្រងៈ**

**ក១**-លោក/អ្នកនឹងត្រូវបង្រៀននៅសាលាបឋមសិក្សា......................................ថ្នាក់ដែលត្រូវបង្រៀននិងត្រូវទទួលបន្ទុក គឺផ្អែកទៅតាមការចាត់តាំង ដែលនឹងត្រូវកំនត់ជាក្រោយ ។

**ក២**- លោក/អ្នកនឹងត្រូវបង្រៀនទៅតាមពេលវេលា ដូចគ្នានឹងគ្រូក្របខ័ណ្ឌក្នុងសាលា គឺអាចបង្រៀនពេលព្រឹក ឬពេលល្ងាច ទៅតាមតំរូវការជាក់ស្តែងរបស់សាលា។ ក្រៅពីការបង្រៀន លោក/អ្នកនឹងត្រូវចូលរួមក្នុងវគ្គបំប៉ននិងការប្រជុំបច្ចេកទេសប្រចាំខែ ព្រមទាំងការងារមួយចំនួនទៀតដែលជាភារកិច្ចទូទៅរបស់គ្រូបង្រៀន ដូចជាការគ្រប់គ្រងថ្នាក់រៀន ការធ្វើទំនាក់ទំនងជាមួយមាតាបិតា ការរួមចំណែកថែរក្សាសម្បត្តិសាលារៀនជាដើម ។ល។

**ក៣**-លោក/អ្នកនឹងស្ថិតនៅក្រោមការគ្រប់គ្រងផ្នែកបច្ចេកទេសនិងរដ្ឋបាល របស់នាយកសាលា។ ក្នុងនោះដែរ គណៈកម្មាធិការអប់រំសម្រាប់ទាំងអស់គ្នាថ្នាក់ឃុំ មានតួនាទីត្រួតពិនិត្យនិងគាំទ្រការងាររបស់លោក/អ្នក លើផ្នែកមួយចំនួនទាក់ទងជាពិសេសទៅនឹងការងាររដ្ឋបាល ដូចជាបញ្ហាវត្តមានគ្រូនិងសិស្សជាដើម ដោយមានការសហការជាមួយនាយកសាលា។

**ខ-ប្រាក់ឧបត្ថម្ភ ៖** លោក/ អ្នកនឹងទទួលប្រាក់ឧបត្ថម្ភចំនួន ១៨ ដុល្លា ក្នុងមួយខែ ហើយបើកនៅរៀងរាល់ដំណាច់ខែនិមួយៗ ដោយគិត៩ខែ ក្នុង១ឆ្នាំសិក្សា។

**គ-ការពិពណ៌នាអំពីការទទួលខុសត្រូវ ៖** ការងារដែលលោកអ្នកត្រូវទទួលខុសត្រូវ មានចែងក្នុងចំនុចក២។ លោក/អ្នកក៏នៅមានការទទួលខុសត្រូវខ្លះទៀត ដែលពុំបានបញ្ចូលក្នុងការពិពណ៌នានេះ ។

*គ១-ការបញ្ឈប់ពីការងារ: កម្មវិធីអេស្កាប់នឹងពិគ្រោះយោបល់ជាមួយគណៈកម្មាធិការអប់រំសម្រាប់ទាំងអស់គ្នា ថ្នាក់ឃុំ និងគណៈកម្មការកំរងមូលដ្ឋាន ដើម្បីធ្វើការពិនិត្យ ពិភាក្សាគ្នាទៅលើការសុំឈប់ ឬបញ្ឈប់ការងាររបស់លោក, អ្នកក្នុងអំឡុងពេលនៃកិច្ចសន្យា ក្នុងករណី ដែលលោក, អ្នកមិនអាចទទួលខុសត្រូវក្នុងការងារ ឬបង្កអោយមានបញ្ហាប៉ះពាល់ដល់ការងាររបស់កម្មវិធី ដោយស្នើយោបល់ទៅក្រុមការងារថ្នាក់ខេត្ត ដើម្បីសម្រេច ។*

**គ២- រយៈពេលនៃកិច្ចសន្យា:** កិច្ចសន្យានេះមានរយៈពេលពីរឆ្នាំ គឺគិតតាមកាលបរិច្ឆេទដែលបានកំនត់ក្នុងកថាខ័ណ្ឌខាងលើ។ **នៅពេលកិច្ចសន្យាត្រូវបានបញ្ចប់ក្រោយពីបំរើការងាររយៈពេលពីរឆ្នាំ សាម៉ីខ្លួននឹងត្រូវរំសាយពីការងារ ហើយត្រូវបានជំនួសដោយគ្រូក្របខ័ណ្ឌ ដែលចេញពីសាលាគរុកោសល្យ ។**

ខ្ញុំបានអានកិច្ចសន្យានេះ ហើយខ្ញុំមានបំនងយល់ព្រមទទួលយកនូវរាល់ល័ក្ខខ័ណ្ឌដែលមាន ហើយខ្ញុំយល់ព្រមអនុវត្តតាមល័ក្ខខ័ណ្ឌទាំងនោះ ។

| | |
|---|---|
| ហត្ថលេខានិងឈ្មោះប្រធានភូមិ | ហត្ថលេខានិងឈ្មោះសាម៉ីខ្លួន |
| ថ្ងៃទី _____ខែ_________ ឆ្នាំ២០០៥ | ថ្ងៃទី _____ខែ_________ ឆ្នាំ២០០៥ |
| ហត្ថលេខានិងឈ្មោះមេឃុំ | ហត្ថលេខានិងឈ្មោះនាយកសាលា |
| ថ្ងៃទី _____ខែ_________ ឆ្នាំ២០០៥ | ថ្ងៃទី _____ខែ_________ ឆ្នាំ២០០៥ |
| ហត្ថលេខានិងឈ្មោះតំណាងក្រុមការងារថ្នាក់ខេត្ត | ហត្ថលេខានិងឈ្មោះអ្នកសម្របសម្រួលថ្នាក់ខេត្ត កម្មវិធីអេស្កាប់ |
| ថ្ងៃទី _____ខែ_________ ឆ្នាំ២០០៥ | ថ្ងៃទី _____ខែ_________ ឆ្នាំ២០០៥ |

**HO. 10**

## សកម្មភាពក្នុងជំហានបន្ទាប់  ក្នុងការជ្រើសរើសគ្រូសហគមន៍

- បើកប្រាក់បុរេប្រទាន ដើម្បីប្រតិបត្តិការងារ ។
- ប្រជុំថ្នាក់ភូមិ /ឃុំ ដើម្បីផ្សព្វផ្សាយពីការជ្រើសរើសគ្រូសហគមន៍ ( ប្រសិនបើកំរង យល់ថាចាំបាច់ត្រូវប្រជុំ) ។
- ធ្វើទំនាក់ទំនងជាមួយវត្តអារាម ព្រះសង្ឃ និង អាចារ្យវត្ត ។
- *ធ្វើទំនាក់ទំនងជាមួយវិហារឥស្លាម និង អ៊ីម៉ាំ (IMAM)  (ចំពោះកំរងដែលមានជនជាតិឥស្លាមច្រើន) ។*
- *ធ្វើទំនាក់ទំនងជាមួយចាស់ទុំក្នុងភូមិ ឬមេកន្ទ្រាញ ចំពោះកំរងដែល មានជនជាតិភាគតិច ។*
- ផ្សាយដំណឹងជ្រើសរើស ។
- ទទួលពាក្យ និង ប្រមូលពាក្យសុំបំរើការងារ ។ ធ្វើបញ្ជីឈ្មោះបេក្ខជនដែលបានដាក់ពាក្យសុំបំរើការងារ ។
- ធ្វើបញ្ជីរាយនាមបេក្ខជនដែលត្រូវសំភាសន៍ ។
- កំនត់ថ្ងៃអញ្ជើញបេក្ខជនមកសំភាសន៍ ។
- រៀបចំទំរង់ទាំងអស់ដែលត្រូវប្រើ ។
- ធ្វើការសំភាសន៍បេក្ខជនដែលជាប់ឈ្មោះក្នុងបញ្ជីសង្ខេប ។
- គណៈកម្មការជ្រើសរើស ធ្វើការបូកសរុបពិន្ទុនិងជ្រើសរើសបេក្ខជន ។
- ស្រង់ឈ្មោះអ្នកជាប់ ហើយបញ្ជូនបញ្ជីឈ្មោះគ្រូសហគមន៍ដែលបានជ្រើសរើសទៅការិយាល័យអប់រំ /ក្រុមការងារថ្នាក់ខេត្ត ( ភ្ជាប់ជាមួយនូវពាក្យសុំរបស់បេក្ខជនដែលជាប់ ហើយរក្សាទុកឯកសារផ្សេងៗទៀតទាក់ទងនឹងការជ្រើសរើសនៅកំរងសាលា រួមមានដូចជាពាក្យសុំនិងលទ្ធផលសំភាសន៍ របស់បេក្ខជនដែលបានដាក់ពាក្យទាំងអស់ជាដើម ។
- ទូទាត់ប្រាក់បុរេប្រទាន ។
- ជួបជាមួយគ្រូសហគមន៍ ដើម្បីចុះកិច្ចសន្យា ។
- ផ្តល់ព័ត៌មានដល់គ្រូសហគមន៍ អំពីថ្ងៃបើកវគ្គបំប៉ន ដែលផ្តល់ដោយអេស្កាប់ អញ្ជើញពួកគេឱ្យចូលរួមក្នុងវគ្គនោះ ។

## តារាងផែនការជ្រើសរើសគ្រូសហគមន៍

**HO. 11**

| សកម្មភាព | ខែ----------------------------------- | | | | | | | | | | | | | | | | | | | | | | | | | | | | | អ្នកទទួលខុសត្រូវ | ធនធានដែលត្រូវការ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |